ព្រះរាជាណាចក្រកម្ពុជា

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

# របាយការណ៍ប្រចាំឆមាសទី១

# ស្តីពី

# ការអនុវត្តផែនការសកម្មភាព និងថវិកា

# របស់ គ.ជ.អ.ប ឆ្នាំ២០១៤

រៀបចំដោយលេខាធិការដ្ឋាន គ.ជ.អ.ប

ខែកក្កដា ឆ្នាំ២០១៤

# មាតិកា

**សេចក្តីសង្ខេប** ........ 01

I. **សេចក្តីផ្តើម** ........ 06

II. **វឌ្ឍនភាព បញ្ហាប្រឈម និងដំណោះស្រាយនានា** ........ 08

១.ការពង្រឹងការគ្រប់គ្រងការអនុវត្តកម្មវិធី ........ 08

២.ការអនុវត្តមូលនិធិក្រុង ស្រុក ........ 11

៣.ប្រភពចំណូលផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ........ 13

៤. ការផ្ទេរមុខងារ. ........ 14

៥. គណនេយ្យភាពសង្គម. ........ 17

៦. លក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ. ........ 18

៧. យុទ្ធសាស្ត្រពង្រឹងតួនាទី និងសិទ្ធិអំណាចរបស់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ. ........ 20

៨. ប្រព័ន្ធកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ. ........ 23

៩. ការពង្រឹងប្រព័ន្ធត្រួតពិនិត្យមើលពីលើ ឬអធិការកិច្ច ........ 24

១០. យុទ្ធសាស្ត្រសម្រាប់ការពង្រឹងសមត្ថភាពផ្ទៃករដ្ឋបាលរបស់ក្រុង ស្រុក. ........ 25

១១. សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ. ........ 26

១២. ការបញ្ជ្រាបយេនឌ័រ និងការពង្រឹងភាពអង់អាចដល់ស្ត្រី ........ 27

១៣. ការរៀបចំតាក់តែង ជអ៣ ដំណាក់កាលបន្ទាប់នៃកម្មវិធីជាតិ. ........ 28

III. **សេចក្តីសន្និដ្ឋាន** ........ 29

# សេចក្តីសង្ខេប

របាយការណ៍ប្រចាំឆមាសទី១ឆ្នាំ២០១៤ ស្តីពីវឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ២០១៤ របស់ គ.ជ.អ.ប ផ្តោតជាសំខាន់លើវឌ្ឍនភាព និងបញ្ហាប្រឈមជាគន្លឹះនៃការអនុវត្តសកម្មភាពអាទិភាពចំនួន១៣ដែលបានកំណត់នៅក្នុងឯកសារពន្យារពេលផអ៣ឆ្នាំ២០១៤ ដោយប្រៀបធៀបទៅនឹងសូចនាករនៃចំណុចដៅជាក់លាក់ដែលបានកំណត់តាមអាទិភាពនីមួយៗ ព្រមទាំងលើកឡើងនូវដំណោះស្រាយចាំបាច់នានាដែលត្រូវផ្តោតការយកចិត្តទុកដាក់ក្នុងការពង្រឹងប្រសិទ្ធភាពនៃការអនុវត្តក្នុងឆមាសទី២ ដើម្បីធានាដល់ការសម្រេចបាននូវអាទិភាពទាំង១៣នៅចុងឆ្នាំ២០១៤។

ស្ថានភាពនៃការអនុវត្តសកម្មភាពអាទិភាពទាំង១៣ នៅក្នុង០៦ខែដើមឆ្នាំ២០១៤នេះ មានរៀបរាប់ជាសង្ខេបដូចខាងក្រោម៖

**១. ការពង្រឹងការគ្រប់គ្រងការអនុវត្តកម្មវិធី៖** ផ្តោតទៅលើការពង្រឹងយន្តការ គ.ជ.អ.ប ក្នុងការដឹកនាំសម្របសម្រួល និងគាំទ្រដល់ការអនុវត្តកម្មវិធីកំណែទម្រង់ឲ្យកាន់តែមានប្រសិទ្ធភាពដោយការបង្កើនភាពជាម្ចាស់របស់ក្រសួង ស្ថាប័នពាក់ព័ន្ធនានាទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ សូចនាករសំខាន់ពាក់ព័ន្ធនឹងកិច្ចការនេះ គឺការធានាដល់ការរៀបចំកិច្ចប្រជុំយ៉ាងទៀងទាត់ទាំងកម្រិតនយោបាយ និងកម្រិតបច្ចេកទេសដើម្បីជំរុញ និងគាំទ្រដល់កិច្ចដំណើរការកំណែទម្រង់។

ផ្អែកលើស្ថានភាពនៃការអនុវត្តជាក់ស្តែង ទោះបីកិច្ចប្រជុំកម្រិតនយោបាយពុំត្រូវបានរៀបចំយ៉ាងទៀងទាត់ដោយសារហេតុផលចាំបាច់មួយចំនួនក៏ដោយ ក៏កិច្ចប្រជុំកម្រិតបច្ចេកទេសត្រូវបានរៀបចំឡើងជាប្រចាំ ដែលធានាបាននូវភាពរលូនក្នុងការគាំទ្រ និងសម្របសម្រួលការអនុវត្តកិច្ចដំណើរការកំណែទម្រង់ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

ដើម្បីធានាដល់ការសម្រេចបានជាស្ថាពរនូវចំណុចដៅដែលបានកំណត់ នៅក្នុង០៦ខែបន្ទាប់ លេខាធិការដ្ឋាន គ.ជ.អ.ប ត្រូវបន្តផ្តោតការយកចិត្តទុកដាក់ទៅលើការធ្វើបច្ចុប្បន្នភាពនៃសមាសភាព គ.ជ.អ.ប និងអនុគណៈកម្មាធិការនានានៃគ.ជ.អ.ប និងពង្រឹងបន្ថែមនូវយន្តការគាំទ្រដល់អនុគណៈកម្មាធិការនានាទាំងនោះ ឱ្យមានដំណើរការតាមតួនាទី និងភារកិច្ចដែលបានកំណត់។

**២. ការអនុវត្តមូលនិធិក្រុង ស្រុក៖** ផ្តោតលើការធានាថា ប្រព័ន្ធផ្ទេរមូលនិធិ និងគ្រប់គ្រងហិរញ្ញវត្ថុក្រុង ស្រុកត្រូវបានអនុវត្តយ៉ាងពេញលេញនៅដើមឆ្នាំ២០១៤។ សូចនាករពាក់ព័ន្ធនឹងសកម្មភាពជាអាទិភាពនេះ គឺការដាក់ចេញនូវសេចក្តីណែនាំស្តីពីវិធីសាស្ត្រ និងនីតិវិធីលទ្ធកម្មក្រុង ស្រុក និងការបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុក្រុង ស្រុកដល់រដ្ឋបាលក្រុង ស្រុកទាំងអស់។

ស្ថានភាពនៃការអនុវត្តកិច្ចការនេះ អាចវាយតម្លៃបានថា បានសម្រេចស្ទើរតែទាំងស្រុងតាមសូចនាករដែលបានកំណត់ ពោលគឺ សេចក្តីណែនាំស្តីពីវិធីសាស្ត្រ និងនីតិវិធីលទ្ធកម្មក្រុង ស្រុកត្រូវបានរៀបចំ និងដាក់ឲ្យអនុវត្ត ព្រមទាំងបានផ្តល់ការបណ្តុះបណ្តាលដល់មន្ត្រីរដ្ឋបាលក្រុង ស្រុក និងអ្នកពាក់ព័ន្ធនានា។ ទោះជាយ៉ាងនេះក្តី ក៏ក្នុងការអនុវត្តជាក់ស្តែងបានជួបប្រទះនូវបញ្ហាចម្បងៗមួយចំនួនដែលត្រូវផ្តោតការយកចិត្តទុកដាក់កែលំអបន្ថែមនៅក្នុងរយៈពេល០៦ខែបន្ទាប់។

៣. **ប្រភពចំណូលផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ៖** ផ្តោតទៅលើការបង្កើតនូវប្រភពចំណូលផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីលើកកម្ពស់ភាពជាម្ចាស់ និងការទទួលខុសត្រូវរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការប្រមូល ការគ្រប់គ្រង និងការប្រើប្រាស់ចំណូលសម្រាប់ការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋានប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងការចូលរួមរបស់ប្រជាពលរដ្ឋ។ សូចនាករសំខាន់ដែលបានកំណត់សម្រាប់ការអនុវត្តក្នុងរយៈពេល០៦ដើមឆ្នាំនេះ គឺការរៀបចំបញ្ចប់ និងការអនុម័តនូវឯកសារគោលនយោបាយស្តីពីប្រភពចំណូលផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយផ្អែកលើរបាយការណ៍នៃការសិក្សាវាយតម្លៃក្នុងរយៈពេលកន្លងមក។

ផ្អែកតាមស្ថានភាពនៃការអនុវត្តជាក់ស្តែងលើកិច្ចការនេះ អាចពិនិត្យឃើញថា ពុំទាន់បានសម្រេចតាមសូចនាករដែលបានកំណត់ឡើយ។ ទោះបីមានការពិនិត្យ ពិភាក្សាច្រើនលើកច្រើនសារក្នុងកម្រិតបច្ចេកទេសក្តី ក៏ពុំទាន់ឈានទៅដល់ការឯកភាពគ្នាជារួមក្នុងការកំណត់នូវជម្រើសសមស្របនានាដើម្បីធ្វើជាមូលដ្ឋានក្នុងការរៀបចំបញ្ចប់នូវឯកសារគោលនយោបាយស្តីពីប្រភពចំណូលផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីដាក់ជូនថ្នាក់នយោបាយពិនិត្យ និងអនុម័តឡើយ។

៤. **ការផ្ទេរមុខងារ៖** ផ្តោតលើការជំរុញឲ្យមានការផ្ទេរមុខងារជាបណ្តើរៗឱ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិ សំដៅបង្វិតសេវាឱ្យទៅកៀកជិតប្រជាពលរដ្ឋ ក្នុងន័យលើកកម្ពស់បរិមាណ គុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ ឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋយ៉ាងពិតប្រាកដ។ សូចនាករសំខាន់ចំពោះកិច្ចការនេះ គឺការរៀបចំបញ្ចប់នូវរបាយការណ៍ស្តីពីការពិនិត្យមើលឡើងវិញនូវមុខងាររបស់ក្រសួងដែលស្ថិតក្នុងវិស័យអាទិភាពចំនួន៥ និងការរៀបចំ និងអនុម័តលិខិតបទដ្ឋានគតិយុត្តស្តីពីមុខងារជាជម្រើសរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីជំរុញឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិផ្តួចផ្តើមគំនិតក្នុងការអនុវត្តមុខងារជាអាណត្តិទូទៅរបស់ខ្លួន។

ផ្អែកតាមស្ថានភាពជាក់ស្តែង ទោះបីការអនុវត្តកិច្ចការនេះពុំទាន់ត្រូវសម្រេចបានទាំងស្រុងតាមសូចនាករដែលបានកំណត់ក្តី ក៏ពិនិត្យឃើញថា មានវឌ្ឍនភាពគួរឲ្យកត់សម្គាល់ គួយ៉ាង ក្រសួងចំនួន៣ រួមមាន ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងអប់រំ យុវជន និងកីឡាបានរៀបចំបញ្ចប់ជាស្ថាពរនូវរបាយការណ៍ពិនិត្យមើលឡើងវិញនូវមុខងាររបស់ខ្លួន និងក្រសួងចំនួន២ផ្សេងទៀតក៏កំពុងស្ថិតក្នុងដំណាក់កាលរៀបចំបញ្ចប់របាយការណ៍របស់ខ្លួនផងដែរ។ ជាមួយគ្នានេះដែរ សេចក្តីព្រាងអនុក្រឹត្យស្តីពីការជ្រើសរើស ការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារជាជម្រើសដោយរដ្ឋបាលថ្នាក់ក្រោមជាតិ ក៏ត្រូវបានរៀបចំ និងត្រៀមដាក់ឆ្លងកិច្ចប្រជុំលើកទី៩របស់ គ.ជ.អ.ប។

៥. **គណនេយ្យភាពសង្គម ៖** ផ្តោតលើការពង្រឹងនូវការប្រើប្រាស់សិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការចូលរួមពង្រឹងការចាត់ចែង ការប្រើប្រាស់ធនធាន និងការផ្តល់សេវានៅរដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈការបង្កលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋក្នុងការទទួលបាននូវព័ត៌មាន និងចូលរួមតាមដានត្រួតពិនិត្យលើការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ សូចនាករសំខាន់ពាក់ព័ន្ធនឹងកិច្ចការនេះ គឺ

ការរៀបចំអនុវត្តសាកល្បងនូវឧបករណ៍នានាដើម្បីធ្វើជាមូលដ្ឋានក្នុងការរៀបចំលិខិតបទដ្ឋានគតិយុត្ត និងសៀវភៅណែនាំសម្រាប់អនុវត្តការងារគណនេយ្យភាពសង្គមនៅតាមស្រុកគោលដៅ។

ផ្អែកតាមស្ថានភាពនៃការអនុវត្តជាក់ស្តែង អាចវាយតម្លៃបានថា សូចនាករទាំងនេះត្រូវបានសម្រេចទាំងស្រុង ពោលគឺឧបករណ៍ចាំបាច់នានា រួមមាន ឯកសារបណ្តុះបណ្តាល ប័ណ្ណផ្តល់ពិន្ទុរបស់ប្រជាពលរដ្ឋ ឧបករណ៍សម្រាប់ប្រមូលព័ត៌មាន ផ្ទាំងរូបភាពផ្សព្វផ្សាយព័ត៌មាន និងកូនសៀវភៅតូចៗដែលងាយយល់ និងងាយប្រើប្រាស់នូវព័ត៌មានសំខាន់ៗពាក់ព័ន្ធនឹងសិទ្ធិរបស់ប្រជាពលរដ្ឋ ស្តង់ដារនៃការផ្តល់សេវា ការប្រើប្រាស់ថវិកា និងការអនុវត្តការងារនានា ត្រូវបានរៀបចំ និងអនុវត្តសាកល្បងនៅក្នុងស្រុកគោលដៅនានា។

**៦. លក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ៖** ផ្តោតលើការបង្កើតប្រព័ន្ធគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិជាលក្ខណៈអចិន្ត្រៃយ៍ ដើម្បីផ្តល់នូវស្វ័យភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រង ចាត់ចែងមន្ត្រី បុគ្គលិករបស់ខ្លួន សំដៅពង្រឹងគណនេយ្យភាពរបស់មន្ត្រី បុគ្គលិកទាំងនោះ ចំពោះរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្តតួនាទី ភារកិច្ច និងផ្តល់សេវាជូនប្រជាពលរដ្ឋ។ សូចនាករសំខាន់ពាក់ព័ន្ធនឹងកិច្ចការនេះ គឺការរៀបចំ និងអនុម័តនូវលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ។

ផ្អែកតាមស្ថានភាពនៃការអនុវត្តជាក់ស្តែង ទោះបីពុំទាន់សម្រេចបានតាមសូចនាករដែលបានកំណត់ទាំងស្រុង ដោយសារមូលហេតុចាំបាច់មួយចំនួន ក៏ពិនិត្យឃើញថា មានវឌ្ឍនភាពគួរឲ្យកត់សម្គាល់ ពោលគឺសេចក្តីព្រាងបឋមនៃលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ និងបានដាក់ឆ្លងកិច្ចប្រជុំអន្តរក្រសួងជាច្រើនលើកច្រើនសារ។ ក៏ប៉ុន្តែដោយសារមានភាពចាំបាច់របស់រាជរដ្ឋាភិបាលដែលតម្រូវឱ្យមានការកែសម្រួលនូវគោលការណ៍រួមស្តីពីការរៀបចំមុខងារសាធារណៈរបស់រដ្ឋ ដើម្បីកែលំអប្រព័ន្ធគ្រប់គ្រងមន្ត្រីរាជការទូទាំងប្រទេស អាស្រ័យហេតុនេះ សេចក្តីព្រាងលក្ខន្តិកៈដែលបានរៀបចំរួចហើយនេះ ពុំត្រូវបានបន្តដំណើរការដើម្បីដាក់ជូន គ.ជ.អ.ប និងរាជរដ្ឋាភិបាលពិនិត្យ អនុម័ត តាមពេលវេលាដែលបានកំណត់ឡើយ។

**៧. យុទ្ធសាស្ត្រពង្រឹងតួនាទី និងសិទ្ធិអំណាចរបស់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ៖** ផ្តោតលើការជំរុញការអនុវត្តតួនាទី និងសិទ្ធិអំណាចរបស់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ សំដៅពង្រឹងតម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាពក្នុងការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តនូវមុខងារ ដើម្បីឆ្លើយតបទៅនឹងតម្រូវការនានារបស់ប្រជាពលរដ្ឋ។ សូចនាករសំខាន់ពាក់ព័ន្ធនឹងកិច្ចការនេះ គឺការរៀបចំលិខិតបទដ្ឋានគតិយុត្ត និងឯកសារបច្ចេកទេសចំនួន០៧ ដែលពាក់ព័ន្ធនឹងការគាំទ្រ និងការពង្រឹងការអនុវត្តតួនាទី និងសិទ្ធិអំណាចរបស់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ។

ផ្អែកតាមស្ថានភាពនៃការអនុវត្តជាក់ស្តែង ជារួម អាចវាយតម្លៃបានថា ស្ទើរសម្រេចបានទាំងស្រុងតាមសូចនាករដែលបានកំណត់ ពោលគឺ ឯកសារបច្ចេកទេសចំនួន០៥ត្រូវបានរៀបចំតាមជំហានដែលបានគ្រោង និងសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ ការកែប្រែ និងការលុបចោលដីការបស់ក្រុម

ប្រឹក្សាត្រូវបានរៀបចំបញ្ចប់ និងត្រៀមដាក់ឆ្លងកិច្ចប្រជុំលើកទី៩របស់ គ.ជ.អ.ប ពិនិត្យនិងសម្រេច។ ដោយឡែកការរៀបចំសេចក្តីព្រាងគំរូវិធានផ្ទៃក្នុងរបស់រដ្ឋបាលក្រុង ស្រុក នៅពុំទាន់ត្រូវបានសម្រេចតាមផែនការ និងត្រូវលើកទៅរៀបចំនៅក្នុងឆមាសបន្ទាប់។

៨. **ប្រព័ន្ធកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ៖** ផ្តោតទៅលើការកែលំអនូវប្រព័ន្ធកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ឲ្យមានលក្ខណៈឆ្លុះបញ្ចាំងយ៉ាងសមស្របទៅតាមចរិតលក្ខណៈផ្សេងៗគ្នានៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ និងធានានូវការដាក់បញ្ចូលនូវផែនការរបស់វិស័យនានាដែលប្រតិបត្តិការក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ សូចនាករសំខាន់ពាក់ព័ន្ធនឹងកិច្ចការនេះ គឺការរៀបចំ និងដាក់ចេញនូវឯកសារគោលនយោបាយស្តីពីប្រព័ន្ធកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

ជារួម ផ្អែកតាមស្ថានភាពនៃការអនុវត្តជាក់ស្តែង អាចវាយតម្លៃបានថា សូចនាករនេះត្រូវបានសម្រេចស្ទើរតែទាំងស្រុង ពោលគឺសេចក្តីព្រាងឯកសារគោលនយោបាយស្តីពីប្រព័ន្ធកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ និងត្រៀមដាក់ឆ្លងកិច្ចប្រជុំលើកទី៩របស់ គ.ជ.អ.ប ដើម្បីពិនិត្យ និងសម្រេច។

៩. **ការពង្រឹងប្រព័ន្ធត្រួតពិនិត្យមើលពីលើ ឬអធិការកិច្ច៖** ផ្តោតលើការពង្រឹងប្រព័ន្ធត្រួតពិនិត្យមើលពីលើ គឺដើម្បីធានាថា រដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់គ្រង ចាត់ចែងអនុវត្តនូវមុខងារ និងធនធានផ្ទាល់របស់ខ្លួន ព្រមទាំងមុខងារដែលបានផ្ទេរឲ្យ ស្របតាមគោលការណ៍ និងនីតិវិធីនានាដែលបានកំណត់។ សូចនាករសំខាន់ពាក់ព័ន្ធនឹងកិច្ចការនេះ គឺការសិក្សាដើម្បីរៀបចំលិខិតបទដ្ឋានគតិយុត្តនានាសម្រាប់ការពង្រឹងប្រព័ន្ធត្រួតពិនិត្យមើលពីលើ ឬអធិការកិច្ច។

ផ្អែកតាមស្ថានភាពជាក់ស្តែង ការអនុវត្តកិច្ចការនេះពុំត្រូវបានសម្រេចតាមសូចនាករដែលបានគ្រោងទុកឡើយ គឺមានភាពយឺតយ៉ាវដោយសារមូលហេតុជាក់ស្តែងមួយចំនួន។ កិច្ចការនេះ ត្រូវបន្តអនុវត្តនៅក្នុងឆមាសបន្ទាប់។

១០. **យុទ្ធសាស្ត្រសម្រាប់ការពង្រឹងសមត្ថភាពផ្នែករដ្ឋបាលរបស់ក្រុង ស្រុក៖** ផ្តោតលើការបន្តពង្រឹងសមត្ថភាពផ្នែករដ្ឋបាលរបស់ក្រុង ស្រុក ដើម្បីធានាដល់ការអនុវត្តតួនាទីរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព។ សូចនាករពាក់ព័ន្ធនឹងកិច្ចការនេះ គឺការវិភាជន៍ថវិកាកម្មវិធីឱ្យទៅរដ្ឋបាលក្រុង ស្រុកសម្រាប់គាំទ្រដល់ការជ្រើសរើសមន្ត្រីកិច្ចសន្យា និងការអនុវត្តសកម្មភាពជាក់លាក់នានាដែលពុំអាចរ៉ាប់រងដោយមូលនិធិក្រុង ស្រុក និង ការរៀបចំសៀវភៅណែនាំស្តីពីកិច្ចប្រតិបត្តិការរបស់រដ្ឋបាលក្រុង ស្រុក។

ផ្អែកតាមស្ថានភាពជាក់ស្តែង ការអនុវត្តកិច្ចការនេះពុំទាន់ត្រូវបានសម្រេចតាមសូចនាករដែលបានកំណត់ទាំងស្រុងឡើយ។ ទោះបីលេខាធិការដ្ឋាន គ.ជ.អ.ប បានវិភាជថវិកាកម្មវិធីមួយចំនួនសម្រាប់គាំទ្រដល់ក្រុង ស្រុករួចរាល់ក្តី ក៏ស្រុកមួយចំនួន ជាពិសេសនៅតាមតំបន់ដាច់ស្រយាលពុំទាន់ជ្រើសរើសបាននូវមន្ត្រីកិច្ចសន្យាតាមតម្រូវការចាំបាច់របស់ខ្លួននៅឡើយ។ ជាមួយគ្នានេះដែរ ការរៀបចំសៀវភៅណែនាំស្តីពីកិច្ចប្រតិបត្តិការរបស់រដ្ឋបាលក្រុង ស្រុក ក៏ត្រូវបានរៀបចំក្នុងលក្ខណៈជា

សេចក្តីព្រាងបឋមប៉ុណ្ណោះ។ កិច្ចការទាំងនេះត្រូវបន្តអនុវត្តនៅក្នុងឆមាសទី២។

**១១. សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ៖** ផ្តោតលើការបន្តរៀបចំបង្កើតសមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិនៅទូទាំងប្រទេស ។ សូចនាករសំខាន់ពាក់ព័ន្ធនឹងកិច្ចការនេះ គឺការបង្កើតបាននូវសមាគមក្រុមប្រឹក្សាក្រុង ស្រុក និងឃុំ សង្កាត់នៅតាមខេត្តដែលនៅសេសសល់ទាំង១៣ និងការរៀបចំកែសម្រួលរចនាសម្ព័ន្ធនៃអគ្គលេខាធិការដ្ឋានសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាឃុំ សង្កាត់ឱ្យក្លាយទៅជាអគ្គលេខាធិការដ្ឋានសម្រាប់គាំទ្រដល់សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិទាំងពីរ ពោលគឺសមាគមក្រុមប្រឹក្សារាជធានី ខេត្ត និងសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់។

ជារួម ស្ថានភាពនៃការអនុវត្តកិច្ចការនេះ អាចវាយតម្លៃបានថា ត្រូវបានសម្រេចតាមសូចនាករដែលបានកំណត់ ពោលគឺសមាគមក្រុមប្រឹក្សាក្រុង ស្រុក និងឃុំ សង្កាត់នៅទូទាំងប្រទេសត្រូវបានបង្កើត និងរចនាសម្ព័ន្ធនៃអគ្គលេខាធិការដ្ឋានសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាឃុំ សង្កាត់ក៏ត្រូវបានសិក្សាកែសម្រួល និងកំពុងត្រូវបានពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធនានា។

**១២. ការបញ្ជ្រាបយេនឌ័រ និងការពង្រឹងឥទ្ធិពលអាចដល់ស្ត្រី៖** ផ្តោតទៅលើការជំរុញឱ្យស្ថាប័នអនុវត្តកិច្ចដំណើរការកំណែទម្រង់ទាំងអស់ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ឱ្យផ្តោតការយកចិត្តទុកដាក់ទៅលើការលើកកម្ពស់ការចូលរួមរបស់ស្ត្រីនៅក្នុងការអនុវត្តកិច្ចដំណើរការកំណែទម្រង់ ដែលពាក់ព័ន្ធនឹងអាណត្តិ និងវិស័យការងាររបស់ខ្លួន។ សូចនាករសំខាន់ពាក់ព័ន្ធនឹងកិច្ចការនេះ គឺការរៀបចំបញ្ចប់នូវសវនកម្មយេនឌ័រ និងការបញ្ចូលនូវអនុសាសន៍នានានៃការធ្វើសវនកម្មយេនឌ័រទៅក្នុងផអ៣ដំណាក់កាលបន្ទាប់។

ជារួម ផ្អែកតាមស្ថានភាពនៃការអនុវត្ត អាចវាយតម្លៃបានថាសូចនាករនេះត្រូវបានសម្រេច ដែលក្នុងនោះសវនកម្មយេនឌ័រត្រូវបានអនុវត្ត និងអនុសាសន៍នានាដែលបានលើកឡើងក្នុងរបាយការណ៍សវនកម្មយេនឌ័រក៏កំពុងត្រូវបានសិក្សាដើម្បីដាក់បញ្ចូលទៅក្នុងយុទ្ធសាស្ត្រ និងឯកសារលម្អិតនៃផអ៣ដំណាក់កាលទី២។

**១៣. ការរៀបចំតាក់តែង ផអ៣ ដំណាក់កាលបន្ទាប់នៃកម្មវិធីជាតិ៖** សូចនាករសំខាន់សម្រាប់កិច្ចការនេះ គឺការរៀបចំល័ក្ខខ័ណ្ឌការងារសម្រាប់រៀបចំតាក់តែងផអ៣ដំណាក់កាលទី២ និងការជ្រើសរើសក្រុមទីប្រឹក្សា ដើម្បីផ្តល់ការគាំទ្រផ្នែកបច្ចេកទេសក្នុងការចាប់ផ្តើមរៀបចំតាក់តែងផអ៣ដំណាក់កាលទី២នៅត្រីមាសទី៣នៃឆ្នាំនេះ។

សូចនាករនេះត្រូវបានសម្រេចទាំងស្រុងតាមការកំណត់ ដែលក្នុងនោះ ក្របខ័ណ្ឌការងារសម្រាប់ការរៀបចំតាក់តែងផអ៣ដំណាក់កាលទី២ត្រូវបានរៀបចំ និងក្រុមទីប្រឹក្សាចំនួន៥រូបត្រូវបានជ្រើសរើស និងចុះកិច្ចសន្យាជាមួយលេខាធិកាដ្ឋាន គ.ជ.អ.ប។ កិច្ចដំណើរការរៀបចំតាក់តែងផអ៣ដំណាក់កាលទី២នឹងត្រូវចាប់ផ្តើមពីដើមត្រីមាសទី៣តទៅ។

## I. សេចក្តីផ្តើម

ផែនការអនុវត្តបីឆ្នាំដំបូង(ផអ៣៖២០១១-២០១៣)នៃកម្មវិធីជាតិ ផ្តោតជាសំខាន់ទៅលើការរៀបចំបង្កើតនូវក្របខ័ណ្ឌគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត និងនីតិវិធីអនុវត្តនានាដែលជាមូលដ្ឋានគ្រឹះពាក់ព័ន្ធនឹងការអភិវឌ្ឍស្ថាប័ន ការគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្ស ការគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ការផ្ទេរមុខងារទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ការត្រួតពិនិត្យ និងការគាំទ្រដល់ការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងការរៀបចំ និងការអនុវត្តក្របខ័ណ្ឌការងារគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ឱ្យស្របតាមគោលការណ៍គ្រឹះនៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ។

ដោយមានភាពយឺតយ៉ាវនៃការចាប់ផ្តើមអនុវត្តក្នុងឆ្នាំទី១ និងផ្អែកលើស្ថានភាពនៃការអនុវត្តជាក់ស្តែងបានតម្រូវឲ្យមានការពន្យារពេលនៃការអនុវត្ត ផអ៣ មួយឆ្នាំបន្ថែមទៀតរហូតដល់ដំណាច់ឆ្នាំ២០១៤ ដើម្បីផ្តល់លទ្ធភាពក្នុងការរៀបចំបញ្ចប់នូវលទ្ធផលរំពឹងទុកចម្បងៗមួយចំនួនតាមគោលបំណងដែលបានគ្រោងទុក និងដើម្បីផ្តល់ពេលវេលាបន្ថែមសម្រាប់ការរៀបចំផែនការអនុវត្តដំណាក់កាលទី២នៃកម្មវិធីជាតិ។ ឯកសារពន្យារពេល ផអ៣ដែលបានអនុម័ត ដោយ គ.ជ.អ.ប នៅថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១៣ បានកំណត់នូវអាទិភាពជាគន្លឹះនានាចំនួន១៣ ដែលត្រូវសម្រេចឲ្យបាននៅក្នុងឆ្នាំ២០១៤។

ផ្អែកលើឯកសារពន្យារពេលផអ៣នេះ ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ២០១៤របស់គ.ជ.អ.ប ត្រូវបានរៀបចំឡើងដោយផ្តោតជាសំខាន់ទៅលើការកំណត់នូវវិធីសាស្រ្ត សកម្មភាព ធនធានស្ថាប័នទទួលបន្ទុក និងពេលវេលាជាក់លាក់ដើម្បីធានាដល់ការសម្រេចបាននូវអាទិភាពទាំង១៣ ដែលក្នុងនោះរួមមាន៖

១. ការពង្រឹងការគ្រប់គ្រងការអនុវត្តកម្មវិធី
២. ការអនុវត្តមូលនិធិក្រុង ស្រុក
៣. ប្រភពចំណូលផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ
៤. ការផ្ទេរមុខងារ
៥. គណនេយ្យភាពសង្គម
៦. លក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ
៧. យុទ្ធសាស្រ្តពង្រឹងតួនាទី និងសិទ្ធិអំណាចរបស់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ
៨. ប្រព័ន្ធកសាងផែនការ និងថវិកាសម្រាប់ប្រភេទផ្សេងៗគ្នានៃរដ្ឋបាលថ្នាក់ក្រោមជាតិ
៩. ការពង្រឹងប្រព័ន្ធត្រួតពិនិត្យមើលពីលើ ឬអធិការកិច្ច
១០. យុទ្ធសាស្រ្តសម្រាប់ការពង្រឹងសមត្ថភាពផ្នែករដ្ឋបាលរបស់ក្រុង ស្រុក
១១. សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ
១២. ការបញ្ជ្រាបយេនឌ័រ និងការពង្រឹងភាពអង់អាចដល់ស្រ្តី និង
១៣. ការរៀបចំតាក់តែង ផអ៣ ដំណាក់កាលបន្ទាប់នៃកម្មវិធីជាតិ

ជាមួយគ្នានេះដែរ ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ២០១៤ ក៏បានកំណត់នូវចំណុចដៅ និងសូចនាកជាក់លាក់នានាដើម្បីធ្វើជាមូលដ្ឋានសម្រាប់ត្រួតពិនិត្យ តាមដាន និងវាស់វែងនូវស្ថានភាពនៃការអនុវត្ត ព្រមទាំងដើម្បីចាត់វិធានការសមស្រប និងទាន់ពេលវេលាក្នុងការដោះស្រាយបញ្ហាប្រឈមនានាដែលកើតមានឡើងក្នុងពេលអនុវត្ត។

របាយការណ៍ប្រចាំឆមាសទី១ស្តីពីវឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាព និងថវិកាឆ្នាំ២០១៤ របស់ គ.ជ.អ.ប នេះ ផ្តោតជាសំខាន់លើស្ថានភាពនៃការសម្រេចបាននូវអាទិភាពនីមួយៗខាងលើដោយប្រៀបធៀបទៅនឹងសូចនាករនៃចំណុចដៅជាក់លាក់ដែលបានកំណត់តាមអាទិភាពនីមួយៗ ព្រមទាំងបញ្ហាប្រឈមជាគន្លឹះដែលជាឧបសគ្គនៃការសម្រេចបាននូវចំណុចដៅទាំងនោះ និងដំណោះស្រាយចាំបាច់នានាដែលត្រូវផ្តោតការយកចិត្តទុកដាក់ក្នុងការអនុវត្តក្នុងឆមាសទី២ ដើម្បីធានាដល់ការសម្រេចបានជាស្ថាពរនូវអាទិភាពទាំង១៣។

## II. វឌ្ឍនភាព បញ្ហាប្រឈម និងដំណោះស្រាយនានា

ផ្នែកនេះពិពណ៌នាអំពីវឌ្ឍនភាពដែលសម្រេចបានក្នុងការអភិវឌ្ឍន៍ និងការអនុវត្តគោលនយោបាយ ច្បាប់ លិខិតបទដ្ឋានគតិយុត្តតាមអាទិភាពនីមួយៗនៃអាទិភាពទាំង១៣ដែលបានកំណត់ ដោយធ្វើការប្រៀបធៀបនូវវឌ្ឍនភាពដែលសម្រេចបានជាមួយនឹងសូចនាករនានាដែលបានកំណត់ ព្រមទាំងកំណត់នូវបញ្ហាប្រឈមដែលបានជួបប្រទះក្នុងការអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ២០១៤របស់គ.ជ.អ.បក្នុងរយៈពេល០៦ខែដើមឆ្នាំ និងលើកឡើងនូវដំណោះស្រាយនានាដែលត្រូវផ្តោត ការយកចិត្តទុកដាក់ ដើម្បីធានាដល់ការសម្រេចបានជាស្ថាពរនូវចំណុចដៅនៃអាទិភាពទាំង១៣នៅក្នុងរយៈពេល០៦ខែបន្ទាប់។

### ១. ការពង្រឹងការគ្រប់គ្រងការអនុវត្តកម្មវិធី

ការពង្រឹងការគ្រប់គ្រងការអនុវត្តកម្មវិធី គឺជាអាទិភាពគន្លឹះ ដែលផ្តោតជាសំខាន់ទៅលើការបន្តពង្រឹងការអនុវត្តនូវតួនាទី ភារកិច្ចរបស់ គ.ជ.អ.ប និងអនុគណៈកម្មាធិការនានានៃគ.ជ.អ.ប ក្នុងការគ្រប់គ្រង ដឹកនាំ សម្របសម្រួលជាទូទៅលើការអនុវត្តគោលនយោបាយ និងកម្មវិធីនៃកំណែទម្រង់ និងការបន្តពង្រឹងការអនុវត្តតួនាទី ភារកិច្ចរបស់លេខាធិការដ្ឋាន គ.ជ.អ.ប ក្នុងការធានាលើការអនុវត្តនូវសេចក្តីសម្រេចនានារបស់ គ.ជ.អ.ប ឲ្យកាន់តែមានប្រសិទ្ធភាព តាមរយៈការបង្កើនភាពជាម្ចាស់ និងការទទួលខុសត្រូវរបស់ស្ថាប័នអនុវត្តនានាទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។

សូចនាករសំខាន់ៗសម្រាប់វាស់វែងស្ថានភាពនៃការសម្រេចបាននូវអាទិភាពនេះ គឺត្រូវធានាថាកិច្ចប្រជុំរបស់ គ.ជ.អ.ប និងអនុគណៈកម្មាធិការនានានៃ គ.ជ.អ.ប ត្រូវបានរៀបចំយ៉ាងទៀងទាត់ដើម្បីពិនិត្យពិភាក្សា និងធ្វើការសម្រេចចិត្តលើក្របខ័ណ្ឌគោលនយោបាយ ច្បាប់ លិខិតបទដ្ឋានគតិយុត្តចាំបាច់នានា ព្រមទាំងសម្របសម្រួលជាមួយក្រសួង ស្ថាប័ននានាដើម្បីជំរុញឱ្យមានការចូលរួម និងគាំទ្ររបស់ក្រសួង ស្ថាប័នទាំងអស់របស់រាជរដ្ឋាភិបាលលើការអនុវត្តនូវគោលនយោបាយ ច្បាប់ លិខិតបទដ្ឋានគតិយុត្តដែលបានដាក់ចេញ។ លេខាធិការដ្ឋាន គ.ជ.អ.ប ត្រូវរៀបចំកិច្ចប្រជុំប្រចាំត្រីមាសជាមួយស្ថាប័នអនុវត្តជអ៣ឱ្យបានទៀងទាត់ ដោយត្រូវមានរបៀបវារៈច្បាស់លាស់ មានការឯកភាពគ្នា និងមានផែនការសកម្មភាពដែលមានចំណុចដៅ និងក្របខ័ណ្ឌពេលវេលាជាក់លាក់សម្រាប់អនុវត្តនូវកិច្ចការដែលបានឯកភាពគ្នាទាំងនោះ។

**វឌ្ឍនភាព៖**

ក្នុងរយៈពេល០៦ខែដើមឆ្នាំនេះ កិច្ចប្រជុំ គ.ជ.អ.ប និងកិច្ចប្រជុំរបស់អនុគណៈកម្មាធិការនៃ គ.ជ.អ.ប មួយចំនួនពុំត្រូវបានរៀបចំតាមកាលកំណត់ឡើយ។ មូលហេតុសំខាន់ដែលបណ្តាលឲ្យមានការខកខានក្នុងការរៀបចំកិច្ចប្រជុំរបស់ គ.ជ.អ.ប និងអនុគណៈកម្មាធិការមួយចំនួនរបស់ គ.ជ.អ.ប នៅក្នុងដើមឆ្នាំ២០១៤នេះ គឺដោយសារនៅក្នុងនីតិកាលទី៥នៃរដ្ឋសភា មានការកែសម្រួលនូវរចនាសម្ព័ន្ធ និងសមាសភាពថ្នាក់ដឹកនាំនៃក្រសួង ស្ថាប័នមួយចំនួននៃរាជរដ្ឋាភិបាល និងស្ថានភាពមមាញឹករបស់ថ្នាក់ដឹកនាំដែលត្រូវផ្តោតការយកចិត្តទុកដាក់លើកិច្ចការនយោបាយជាអាទិភាពមួយចំនួនដែល

ត្រូវដោះស្រាយ។ ការកែសម្រួលរចនាសម្ព័ន្ធ ការផ្លាស់ប្តូរនូវសមាសភាពនៃថ្នាក់ដឹកនាំរបស់ក្រសួង ស្ថាប័ន និងការវិវត្តទៅកាន់ដំណាក់កាលស៊ីជម្រៅនៃកិច្ចដំណើរការកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ បានតម្រូវឲ្យមានការកែសម្រួល ឡើងវិញនូវសមាសភាពនៃ គ.ជ.អ.ប. និងអនុគណៈកម្មាធិការនៃគ.ជ.អ.ប។ ក្នុង០៦ខែដើមឆ្នាំនេះ លេខាធិការដ្ឋាន គ.ជ.អ.ប បានធ្វើការសិក្សា និងបានរៀបចំនូវលិខិតបទដ្ឋានគតិយុត្តនានាក្នុងការរៀបចំកែសម្រួលនូវសមាសភាពនៃគ.ជ.អ.ប. និងអនុគណៈកម្មាធិការនៃគ.ជ.អ.ប ដើម្បីដាក់ជូន គ.ជ.អ.ប និងរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច។

ដោយឡែក ដើម្បីធានាដល់ការសម្របសម្រួល និងគាំទ្រដល់ស្ថាប័នអនុវត្តជអ៣នានា ក្នុងការអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ២០១៤របស់គ.ជ.អ.ប នៅក្នុងរយៈពេល០៦ខែដើមឆ្នាំនេះ លេខាធិការដ្ឋាន គ.ជ.អ.ប បានរៀបចំនូវកិច្ចប្រជុំចំនួនមួយលើកជាមួយតំណាងរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីពិនិត្យលើស្ថានភាពនៃការអនុវត្តជាក់ស្តែងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងពិគ្រោះពិភាក្សាលើបញ្ហាប្រឈម និងដំណោះស្រាយនានាដែលត្រូវផ្តោតការយកចិត្តទុដាក់ទាំងក្នុងរយៈពេលចំពោះមុខ និងក្នុងរយៈពេល០៦ខែបន្ទាប់។ ជាមួយគ្នានេះដែរ លេខាធិការដ្ឋាន គ.ជ.អ.ប ក៏បានរៀបចំនូវកិច្ចប្រជុំសម្របសម្រួលជាមួយស្ថាប័នអនុវត្តជអ៣នានានៅថ្នាក់ជាតិបានចំនួនមួយលើកផងដែរ ដើម្បីពិនិត្យពិភាក្សាលើវឌ្ឍនភាព និងបញ្ហាប្រឈមជាគន្លឹះដែលបានជួបប្រទះក្នុងការអនុវត្តក្នុងរយៈពេល០៦ខែដើមឆ្នាំ និងដាក់ចេញនូវវិធានការចាំបាច់នានាដើម្បីធានាដល់ការដោះស្រាយបញ្ហាប្រឈម និងធានាដល់ការសម្រេចបាននូវចំណុចដៅនានាដែលជាការទទួលខុសត្រូវរបស់ស្ថាប័នអនុវត្តជអ៣នីមួយៗ ដែលបានកំណត់នៅក្នុងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ២០១៤របស់ គ.ជ.អ.ប។

ក្រៅពីកិច្ចប្រជុំសម្របសម្រួលជាមួយស្ថាប័នអនុវត្តជអ៣ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក្នុងរយៈពេល០៦ខែដើមឆ្នាំនេះ លេខាធិការដ្ឋាន គ.ជ.អ.ប ក៏បានសម្របសម្រួល និងរៀបចំកិច្ចប្រជុំក្រុមការងារបច្ចេកទេសស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការចំនួនពីរលើកតាមការកំណត់ ដើម្បីពិគ្រោះពិភាក្សាជាមួយដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធនានាអំពីស្ថានភាព និងបញ្ហាប្រឈមនៃការអនុវត្ត និងការបន្តពង្រឹងកិច្ចសហប្រតិបត្តិការគាំទ្ររបស់ដៃគូអភិវឌ្ឍន៍ក្នុងកិច្ចដំណើរការកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

**បញ្ហាប្រឈម៖**

ទោះបីជាទូទៅ ការគ្រប់គ្រង ការសម្របសម្រួល និងការគាំទ្រក្នុងការរៀបចំ និងអនុវត្តផែនការសកម្មភាព និងថវិកាឆ្នាំ២០១៤ មានដំណើរការប្រព្រឹត្តទៅដោយរលូនក្តី បើប្រៀបធៀបទៅនឹងសូចនាករនៃចំណុចដៅដែលបានកំណត់ ស្ថានភាពនៃការអនុវត្តក្នុង០៦ខែដើមឆ្នាំចំពោះអាទិភាពនេះពុំទាន់ត្រូវបានសម្រេចទាំងស្រុងតាមការរំពឹងទុកនៅឡើយ ។ បញ្ហាប្រឈមជាគន្លឹះដែលជាហេតុធ្វើឲ្យពុំអាចសម្រេចបានតាមសូចនាករនៃចំណុចដៅដែលបានកំណត់ទាំងនេះ ជាពិសេសសូចនាករដែលពាក់ព័ន្ធនឹងការរៀបចំកិច្ចប្រជុំ គ.ជ.អ.ប និងកិច្ចប្រជុំរបស់អនុគណៈកម្មាធិការនានានៃគ.ជ.អ.ប រួមមាន៖

- នាពេលដើមឆ្នាំនេះ លេខាធិការដ្ឋាន គ.ជ.អ.ប មានកិច្ចការបន្ទាន់ និងអាទិភាពនានាជាច្រើនពាក់ព័ន្ធនឹងការរៀបចំលិខិតបទដ្ឋាននានា ដើម្បីធានាដល់ការគាំទ្រផ្នែកប្រតិបត្តិការដល់ស្ថាប័នអនុវត្តទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិក្នុងការចាប់ផ្តើមអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ២០១៤របស់ គ.ជ.អ.ប។
- មន្ត្រីនៃលេខាធិការដ្ឋាន គ.ជ.អ.ប មានចំនួនតិច ពុំអាចមានលទ្ធភាពរ៉ាប់រងឲ្យបានពេញលេញ និងទាន់ពេលវេលានូវបន្ទុកការងាររបស់លេខាធិការដ្ឋានដែលកាន់តែកើនឡើង និងកាន់តែមានភាពសាំញាំនោះឡើយ ជាពិសេសបន្ទុកការងារពាក់ព័ន្ធនឹងការសម្របសម្រួល និងគាំទ្រដល់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអនុគណៈកម្មាធិការនានានៃ គ.ជ.អ.ប ក្នុងការអភិវឌ្ឍន៍គោលនយោបាយ ច្បាប់ លិខិតបទដ្ឋានគតិយុត្ត ដើម្បីដាក់ឆ្លងកិច្ចប្រជុំ គ.ជ.អ.ប ពិនិត្យ ពិភាក្សា និងសម្រេច។ ទោះបីផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ២០១៤ បានកំណត់ឲ្យជ្រើសរើសមន្ត្រីបន្ថែមតាមអង្គភាពនានានៃលេខាធិការដ្ឋាន គ.ជ.អ.ប ក៏ដោយ ក៏ការជ្រើសរើសមន្ត្រីបន្ថែមទាំងនេះ ត្រូវការពេលវេលាជាក់លាក់មួយ ដើម្បីធានាដល់ការអនុវត្តតាមនីតិវិធីនៃការជ្រើសរើសមន្ត្រីដោយត្រូវផ្អែកលើលក្ខណៈវិនិច្ឆ័យសមស្រប ព្រមទាំងប្រកបដោយការប្រកួតប្រជែង និងតម្លាភាព។

**ដំណោះស្រាយៈ**

ដើម្បីធានាដល់ការសម្រេចបានតាមសូចនាករនានានៃចំណុចដៅដែលបានកំណត់ ក្នុងរយៈពេល០៦ខែបន្ទាប់ លេខាធិការដ្ឋាន គ.ជ.អ.ប ត្រូវផ្តោតការយកចិត្តទុកដាក់លើកិច្ចការសំខាន់ៗមួយចំនួនដូចខាងក្រោមៈ

- រៀបចំបញ្ចប់នូវលិខិតបទដ្ឋាននានាពាក់ព័ននឹងការស្នើសុំកែសម្រួល និងធ្វើបច្ចុប្បន្នភាពសមាសភាព គ.ជ.អ.ប និងអនុគណៈកម្មាធិការនានានៃគ.ជ.អ.ប ដើម្បីដាក់ជូន គ.ជ.អ.ប និងរាជរដ្ឋាភិបាលពិនិត្យសម្រេច នៅក្នុងដើមត្រីមាសទី៣
- ពន្លឿនការជ្រើសរើស តែងតាំងមន្ត្រីដែលបានកំណត់ឱ្យបានចប់ ដើម្បីឲ្យមន្ត្រីទាំងនេះចូលបម្រើការងារតាមអង្គភាពនានានៅដើមត្រីមាសទី៣
- ពង្រឹងយន្តការគាំទ្រដល់អនុគណៈកម្មាធិការនានានៃ គ.ជ.អ.ប តាមរយៈការកំណត់មន្ត្រីជាក់លាក់ឲ្យទទួលខុសត្រូវក្នុងការសម្របសម្រួល និងគាំទ្រដល់អនុគណៈកម្មាធិការនីមួយៗនៃគ.ជ.អ.ប
- ពង្រឹងការអនុវត្តតួនាទីភារកិច្ច និងសមត្ថភាពរបស់អង្គភាពពាក់ព័ន្ធនានានៃលេខាធិការដ្ឋានក្នុងការជួយគាំទ្រដល់រៀបចំកិច្ចប្រជុំ គ.ជ.អ.ប និងកិច្ចប្រជុំសម្របសម្រួលជាមួយស្ថាប័នអនុវត្តផអ៣ ដោយកំណត់ពេលវេលា របៀបវារៈ របាយការណ៍ និងឯកសារពាក់ព័ន្ធនានាឲ្យបានច្បាស់លាស់ដើម្បីធានាថាកិច្ចប្រជុំត្រូវបានធ្វើឡើងតាមការកំណត់។

**២. ការអនុវត្តមូលនិធិក្រុង ស្រុក**

ការរៀបចំ និងដាក់ឲ្យអនុវត្តនូវប្រព័ន្ធ និងនីតិវិធីសម្រាប់ការផ្ទេរ ការគ្រប់គ្រង និងការអនុវត្តមូលនិធិក្រុង ស្រុកប្រកបដោយភាពពេញលេញនៅក្នុងឆ្នាំ២០១៤ គឺជាអាទិភាពដ៏ចម្បងមួយដែលបានកំណត់នៅក្នុងឯកសារពន្យារពេលនៃផអ៣។

ដើម្បីធានាថា មូលនិធិក្រុង ស្រុកត្រូវបានផ្ទេរ គ្រប់គ្រង ប្រើប្រាស់ និងត្រូវបានអនុវត្តយ៉ាងពេញលេញក្នុងឆ្នាំ២០១៤ សកម្មភាពជាអាទិភាពដែលផ្តោតការយកចិត្តទុកដាក់នៅក្នុង០៦ខែដើមឆ្នាំ២០១៤នេះ គឺការរៀបចំដាក់ចេញនូវសេចក្តីណែនាំស្តីពីវិធីសាស្ត្រ និងនីតិវិធីលទ្ធកម្មក្រុង ស្រុក និងការបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុក្រុង ស្រុកដល់រដ្ឋបាលក្រុង ស្រុកទាំងអស់។ សូចនាករសំខាន់ដែលបានកំណត់សម្រាប់វាស់វែងអំពីស្ថានភាពនៃការសម្រេចបាននូវអាទិភាពនេះ គឺរដ្ឋបាលក្រុងស្រុកទាំងអស់ត្រូវបានទទួលការបណ្តុះបណ្តាលអំពីការគ្រប់គ្រងហិរញ្ញវត្ថុក្រុង ស្រុកនៅត្រឹមត្រីមាសទី១ និងគម្រោងអភិវឌ្ឍន៍ក្រុង ស្រុកត្រូវបានធ្វើលទ្ធកម្មដោយប្រើប្រាស់វិធីសាស្ត្រ និងនីតិវិធីលទ្ធកម្មផ្ទាល់របស់រដ្ឋបាលក្រុង ស្រុកចាប់ពីត្រីមាសទី២តទៅ។ ការសម្របសម្រួលដើម្បីរៀបចំ និងអនុវត្តនូវសកម្មភាពជាអាទិភាពទាំងនេះត្រូវបានកំណត់នៅក្នុងផែនការសកម្មភាព និងថវិការបស់អនុកម្មវិធីទី៤ ដែលស្ថិតនៅក្រោមការទទួលខុសត្រូវ និងដឹកនាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**វឌ្ឍនភាព៖**

ក្នុងរយៈពេល០៦ខែដើមឆ្នាំ វឌ្ឍនភាពសំខាន់ៗពាក់ព័ន្ធនឹងការអនុវត្តនូវអាទិភាពនេះ រួមមាន៖

- ការរៀបចំនឹងដាក់ចេញនូវសេចក្តីណែនាំលេខ០០២ សហវ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៤ ស្តីពីវិធីសាស្ត្រ និងនីតិវិធីលទ្ធកម្មរបស់រដ្ឋបាលក្រុង ស្រុក
- ការរៀបចំបង្កើតបាននូវគណៈកម្មាធិការ និងអង្គភាពលទ្ធកម្មនៅរដ្ឋបាលក្រុង ស្រុកទាំងអស់
- ការបណ្តុះបណ្តាលអំពីវិធីសាស្ត្រ និងនីតិវិធីលទ្ធកម្មដល់រដ្ឋបាលក្រុង ស្រុកទាំងអស់
- ការផ្ទេរធនធានមូលនិធិពីគណនីមូលនិធិក្រុង ស្រុកនៅថ្នាក់ជាតិទៅគណនីប្រាក់បញ្ញើរបស់ក្រុង ស្រុកនីមួយៗនៅរតនាគារខេត្ត
- ការដាក់ចេញនូវសារាចរណែនាំពាក់ព័ន្ធនឹងការរៀបចំថវិកាក្រុង ស្រុកសម្រាប់ឆ្នាំ២០១៥។

**បញ្ហាប្រឈម៖**

ទោះបីជាមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ពាក់ព័ន្ធនឹងការអនុវត្តមូលនិធិក្រុង ស្រុក ក៏ប៉ុន្តែកិច្ចការនេះនៅជួបប្រទះបញ្ហាប្រឈមសំខាន់ៗមួយចំនួនដូចខាងក្រោម៖

- ការបណ្តុះបណ្តាលអំពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុក្រុង ស្រុកពុំអាចអនុវត្តបានលើគ្រប់ប្រធានបទពាក់ព័ន្ធដូចដែលបានកំណត់ដោយសារភាពយឺតយ៉ាវនៃការរៀបចំដើម្បីទទួលបាននូវថវិកាគាំទ្រពីប្រភពហិរញ្ញប្បទានដែលជាគម្រោងរបស់ធនាគារអភិវឌ្ឍន៍អាស៊ី។ ក្នុងរយៈពេល០៦ខែដើមឆ្នាំនេះ ដើម្បីដោះស្រាយបញ្ហាជាបន្ទាន់ និងចំពោះមុខក្នុងការធានាឲ្យមាន

ការចាប់ផ្តើមអនុវត្តជាបណ្តើរៗនូវសកម្មភាពបណ្តុះបណ្តាលពាក់ព័ន្ធនឹងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុក្រុង ស្រុក លេខាធិការដ្ឋាន គ.ជ.អ.ប បានអនុញ្ញាតឲ្យប្រើប្រាស់ថវិកាបម្រុងពីប្រភពថវិកាផ្សេងទៀត ដើម្បីគាំទ្រដល់សកម្មភាពបណ្តុះបណ្តាលស្តីពីវិធីសាស្ត្រ និងនីតិវិធីលទ្ធកម្មរបស់រដ្ឋបាលថ្នាក់ក្រុង ស្រុក។

- ក្នុងការអនុវត្តជាក់ស្តែង រដ្ឋបាលក្រុង ស្រុកមួយចំនួនបានប្រើប្រាស់មូលនិធិក្រុង ស្រុកសម្រាប់រ៉ាប់រងស្ទើរតែទាំងស្រុងទៅលើបន្ទុកបុគ្គលិក ចំណាយប្រតិបត្តិការរដ្ឋបាល ការជួសជុល និងការថែទាំអាគារសាលាក្រុង ស្រុក និងចំណាយមិនបានគ្រោងទុក។ ដោយឡែក ការចំណាយសម្រាប់អភិវឌ្ឍន៍មូលដ្ឋាន និងការងារសេវាសង្គមនៅមានកម្រិតទាប។ ការប្រើប្រាស់មូលនិធិក្រុង ស្រុកស្ទើរតែទាំងស្រុងលើបន្ទុកបុគ្គលិក និងកិច្ចការរដ្ឋបាលនេះ ដោយសាររដ្ឋបាលក្រុង ស្រុកទាំងនោះពុំបានដឹងច្បាស់អំពីទំហំជាក់លាក់សម្រាប់សមាសភាពនីមួយៗនៃមូលនិធិក្រុង ស្រុកដែលខ្លួនបានទទួល។
- ការផ្ទេរធនធានមូលនិធិក្រុង ស្រុកប្រចាំត្រីមាសមានភាពយឺតយ៉ាវ ព្រមទាំងការចំណាយ និងការទូទាត់ថវិកាក្រុង ស្រុកភាគច្រើនធ្វើឡើងតាមរយៈរជ្ជទេយ្យបុរេប្រទាន ដែលមានភាពស្មុគស្មាញ និងបង្កលក្ខណៈឲ្យមានភាពមិនប្រក្រតីមួយចំនួន។
- មន្ត្រីនៃការិយាល័យរដ្ឋបាលនិងហិរញ្ញវត្ថុ និងអង្គភាពលទ្ធកម្មរបស់សាលាក្រុង ស្រុក គឺជាមន្ត្រីដែលត្រូវបានធ្វើសមាហរណកម្មពីរចនាសម្ព័ន្ធសាលាក្រុង ស្រុកចាស់មកក្នុងរចនាសម្ព័ន្ធថ្មីរបស់សាលាក្រុង ស្រុក ដែលមានជំនាញ និងបទពិសោធន៍ពាក់ព័ន្ធទៅកិច្ចការថវិកា ហិរញ្ញវត្ថុ និងការងារលទ្ធកម្មនៅមានកម្រិតនៅឡើយ។
- ទោះបីនៅថ្នាក់ខេត្តបានបង្កើតឲ្យមានយន្តការគាំទ្រដល់រដ្ឋបាលក្រុង ស្រុកក្នុងការគ្រប់គ្រងចាត់ចែង ប្រើប្រាស់ និងអនុវត្តថវិកាក្រុង ស្រុក ក៏យន្តការនេះមិនទាន់ដំណើរការពេញលេញនៅឡើយ។ យន្តការនេះមិនទាន់មានលទ្ធភាពជួយគាំទ្រដោយផ្ទាល់តាមក្រុង ស្រុកនីមួយៗ អាស្រ័យហេតុនេះ ក្នុងការអនុវត្តជាក់ស្តែង ក្រុង ស្រុកត្រូវឡើងមកខេត្តដើម្បីសុំជំនួយ ឬការគាំទ្រពីមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬរតនាគារខេត្ត ឬទីចាត់ការហិរញ្ញវត្ថុដោយផ្ទាល់តែម្តងលើបញ្ហានានាដែលពាក់ព័ន្ធនឹងការធ្វើសំណើ ការគ្រប់គ្រង និងការអនុវត្តថវិកា។

**ដំណោះស្រាយៈ**

ដើម្បីធានាដល់ការដោះស្រាយបញ្ហាខាងលើ និងដើម្បីធានាដល់ការសម្រេចបានតាមសូចនាករនានានៃចំណុចដៅដែលបានកំណត់ ក្នុងរយៈពេល០៦ខែបន្ទាប់ ត្រូវផ្តោតការយកចិត្តទុកដាក់លើកិច្ចការសំខាន់ៗមួយចំនួនដូចខាងក្រោមៈ

- ពន្លឿនការរៀបចំវគ្គបណ្តុះបណ្តាលអំពីប្រធានបទពាក់ព័ន្ធនឹងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុក្រុង ស្រុកដល់មន្ត្រីពាក់ព័ន្ធរបស់ក្រុង ស្រុកទាំងអស់
- ជូនដំណឹងជាផ្លូវការអំពីការវិភាជន៍ធនធានប្រចាំឆ្នាំពីមូលនិធិក្រុង ស្រុក ដោយបញ្ជាក់ឲ្យ

បានច្បាស់លាស់អំពីទំហំធនធានសម្រាប់សមាសភាគប្រតិបត្តិការរដ្ឋបាលទូទៅ និងសម្រាប់សមាសភាគអភិវឌ្ឍន៍មូលដ្ឋាន ព្រមទាំងណែនាំដល់រដ្ឋបាលក្រុង ស្រុកឲ្យគ្រោងប្រើប្រាស់ធនធានមូលនិធិវិភាជន៍សម្រាប់សមាសភាគនីមួយៗ ដើម្បីឆ្លើយតបទៅនឹងតម្រូវការនៃការប្រើប្រាស់ធនធានមូលនិធិ ដូចបានកំណត់ក្នុងច្បាប់ លិខិតបទដ្ឋានជាធរមាន។

- ពន្លឿនការរៀបចំដាក់ចេញនូវប្រកាសណែនាំស្តីពីនីតិវិធីផ្ទៀងផ្ទាត់នៃការបំពេញល័ក្ខខ័ណ្ឌសម្រាប់ការផ្ទេរ ទម្រង់របាយការណ៍ចំណូលចំណាយថវិកាដែលបានអនុវត្តនៅត្រីមាសមុនៗ និងទម្រង់របាយការណ៍ប៉ាន់ស្មានចំណូល ចំណាយថវិកាសម្រាប់ត្រីមាសបន្ទាប់ និងឯកសារ គាំទ្រជាមូលដ្ឋាន ដើម្បីផ្តល់ភាពងាយស្រួល និងភាពត្រឹមត្រូវច្បាស់លាស់ដល់រដ្ឋបាលក្រុង ស្រុកក្នុងការរៀបចំសំណើ របាយការណ៍ និងឯកសារពាក់ព័ន្ធឱ្យបានត្រឹមត្រូវនិង ទាន់ពេលវេលា ព្រមទាំងផ្តល់ភាពងាយស្រួល និងច្បាស់លាស់ដល់អភិបាលខេត្ត ក្នុងការផ្ទៀងផ្ទាត់ការបំពេញល័ក្ខខ័ណ្ឌសម្រាប់ការផ្ទេរមូលនិធិក្រុង ស្រុក។
- ពិនិត្យឡើងវិញនូវយន្តការនានាទាំងនៅថ្នាក់ជាតិ និងថ្នាក់ខេត្តក្នុងការគាំទ្រដល់រដ្ឋបាលក្រុង ស្រុក សំដៅកែលំអ ពង្រឹងសមត្ថភាព និងប្រសិទ្ធភាពរបស់យន្តការគាំទ្រទាំងនេះ ក៏ដូចការពង្រឹងសមត្ថភាពរបស់រដ្ឋបាលក្រុង ស្រុកក្នុងការគ្រប់គ្រង និងការអនុវត្តថវិការបស់ខ្លួន។

### ៣. ប្រភពចំណូលផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ

ការរៀបចំបង្កើតនូវប្រភពចំណូលផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ គឺជាគោលបំណងដ៏ចម្បងមួយនៃកិច្ចដំណើការវិមជ្ឈការហិរញ្ញវត្ថុ ហើយក៏ជាសមាសភាពមួយសំខាន់កំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ ការរៀបចំបង្កើតប្រភពចំណូលផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ សំដៅលើកកម្ពស់ភាពជាម្ចាស់ និងការទទួលខុសត្រូវរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការប្រមូល ការគ្រប់គ្រង និងការប្រើប្រាស់ចំណូលសម្រាប់ការផ្តល់សេវា និងការអភិវឌ្ឍនៅតាមមូលដ្ឋានរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងការចូលរួមរបស់ប្រជាពលរដ្ឋ។ ការអនុវត្តជអ៣ក្នុងរយៈពេល៣ឆ្នាំកន្លងមក ការសិក្សាវាយតម្លៃអំពីស្ថានភាព លទ្ធភាព និងជម្រើសនានាសម្រាប់ការកំណត់នូវប្រភពចំណូលផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានរៀបចំដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយមានការគាំទ្រផ្នែកបច្ចេកទេសពីធនាគារអភិវឌ្ឍន៍អាស៊ី។

ដើម្បីធានាដល់ការបង្កើតបាននូវប្រភពចំណូលផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងកម្រិតសមស្របសម្រាប់ការចាប់ផ្តើមអនុវត្តនៅក្នុងឆ្នាំ២០១៥ សូចនាករសំខាន់នៃចំណុចដៅសម្រាប់ការអនុវត្តនៅក្នុងរយៈពេល០៦ខែដើមឆ្នាំនេះ គឺការរៀបចំបញ្ចប់ និងការអនុម័តនូវឯកសារគោលនយោបាយស្តីពីប្រភពចំណូលផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយផ្អែកលើរបាយការណ៍នៃការសិក្សាវាយតម្លៃក្នុងរយៈពេលកន្លងមក។ ការសម្របសម្រួលក្នុងការរៀបចំ និងអនុវត្តនូវសកម្មភាពជាអាទិភាពទាំងនេះត្រូវបានកំណត់នៅក្នុងផែនការសកម្មភាព និងថវិការបស់អនុកម្មវិធីទី៤ ដែលស្ថិតនៅក្រោមការទទួលខុសត្រូវ និងដឹកនាំដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**វឌ្ឍនភាព៖**

ក្នុងរយៈពេល០៦ខែដើមឆ្នាំនេះ ស្ថានភាពនៃការរៀបចំឯកសារគោលនយោបាយស្តីពីប្រភពចំណូលផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ពុំទាន់សម្រេចបានតាមចំណុចដៅដែលបានកំណត់ឡើយ ប៉ុន្តែ ជារួម ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានរៀបចំកិច្ចប្រជុំផ្ទៃក្នុងជាច្រើនលើក ដើម្បីពិនិត្យពិភាក្សាលើជម្រើសនានាពាក់ព័ន្ធនឹងការកំណត់នូវប្រភពចំណូលផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ទោះជាយ៉ាងនេះក្តី ការពិនិត្យពិភាក្សាលើជម្រើសទាំងនោះ ពុំទាន់ឈានដល់ការឯកភាពគ្នាជារួមក្នុងការកំណត់នូវប្រភពចំណូលផ្ទាល់ជាក់លាក់សម្រាប់ប្រភេទរដ្ឋបាលផ្សេងៗគ្នានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធ្វើជាមូលដ្ឋានក្នុងការរៀបចំបញ្ចប់នូវឯកសារគោលនយោបាយស្តីពីប្រភពចំណូលផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិនៅឡើយ។

**បញ្ហាប្រឈម៖**

ទោះបីរបាយការណ៍ស្តីពីលទ្ធផលនៃការសិក្សានានាស្តីពីប្រភពចំណូលផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលបានរៀបចំកន្លងមកបានកំណត់នូវជម្រើស និងការវិភាគអំពីសក្តានុពលនៃប្រភពចំណូលផ្ទាល់នានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្តី ក៏តាមរយៈកិច្ចប្រជុំពិនិត្យពិភាក្សាច្រើនលើកច្រើនសារក្នុងចំណោមអង្គភាពពាក់ព័ន្ធនានានៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅតែពុំអាចឈានទៅរកការឯកភាពគ្នាទៅលើជម្រើសសមស្របណាមួយឡើយ។ ភាពយឺតយ៉ាវនៃការកំណត់នូវប្រភពចំណូលផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិនេះ ធ្វើឲ្យមានការពន្យារពេលនៃការរៀបចំបញ្ចប់ និងការអនុម័តនូវឯកសាគោលនយោបាយដើម្បីផ្តល់ជាផែនទីបង្ហាញផ្លូវសម្រាប់ការរៀបចំបង្កើត និងដាក់ឲ្យអនុវត្តនូវប្រភពចំណូលផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

**ដំណោះស្រាយ៖**

ដើម្បីធានាដល់ការដោះស្រាយនូវបញ្ហាខាងលើ គ.ជ.អ.ប គួររៀបចំឲ្យមានការពិនិត្យពិភាក្សាជាមួយតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធនានា ជាពិសេសជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដើម្បីបញ្ជាក់ឡើងវិញអំពីឆន្ទៈផ្នែកនយោបាយពាក់ព័ន្ធនឹងការរៀបចំបង្កើតប្រភពចំណូលផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងផ្តល់គោលការណ៍ណែនាំតម្រង់ទិសនានាដល់ថ្នាក់បច្ចេកទេស ក្នុងន័យជំរុញដល់កិច្ចដំណើរការរៀបចំសេចក្តីព្រាងឯកសារគោលនយោបាយនេះ ដើម្បីដាក់ជូន គ.ជ.អ.ប ពិនិត្យ និងសម្រេចនៅឆមាសទី២។

**៤. ការផ្ទេរមុខងារ**

ការផ្ទេរមុខងារ និងធនធានឲ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិ គឺជាអាទិភាពដ៏សំខាន់នៃផអ៣។ ការផ្ទេរមុខងារ និងធនធានទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិ គឺសំដៅបង្កិតការផ្តល់សេវាឱ្យទៅកៀកជិតប្រជាពលរដ្ឋ ដើម្បីលើកកម្ពស់ទាំងបរិមាណ គុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ ព្រមទាំងឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាន។ ជារួម កិច្ចដំណើរការនៃការផ្ទេរមុខងារ និងធនធានឲ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិដែលបានអនុវត្តក្នុងរយៈពេល៣ឆ្នាំ

កន្លងមកមាន ភាពយឺតយ៉ាវបើប្រៀបធៀបក្របខ័ណ្ឌពេលវេលាដែលបានកំណត់ដោយអនុក្រឹត្យលេខ ៦៨ អនក្រ.បក ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១២ ស្តីពីកិច្ចដំណើរការទូទៅនៃការផ្ទេរមុខងារ និងធនធានឲ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ក៏ដូចជាបើប្រៀបធៀបទៅនឹងលទ្ធផលរំពឹងទុកដែលបានកំណត់ក្នុងផអ៣ផងដែរ។

ដើម្បីឈានទៅធ្វើការផ្ទេរនូវមុខងារមួយចំនួនពីក្រសួង ស្ថាប័នដែលស្ថិតក្នុងវិស័យអាទិភាពឲ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងលក្ខណៈសាកល្បង ឬអចិន្ត្រៃយ៍ សំដៅលើកទឹកចិត្តឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិប្រើប្រាស់នូវសិទ្ធិអំណាចរបស់ខ្លួនក្នុងការអនុវត្តមុខងារជាកាតព្វកិច្ច និងការជ្រើសរើស និងអនុវត្តមុខងារជាជម្រើសនានាក្នុងការលើកកម្ពស់ការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋានប្រកបដោយគណនេយ្យភាព តម្លាភាព ប្រសិទ្ធភាព សមធម៌ និងឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ២០១៤របស់ គ.ជ.អ.ប បានកំណត់នូវសូចនាករនៃចំណុចដៅចំនួនពីរសំខាន់ដែលត្រូវសម្រេចឲ្យបាននៅក្នុង០៦ខែដើមឆ្នាំ។ សូចនាករនៃចំណុចដៅទាំងនោះពាក់ព័ន្ធនឹង ១) ការរៀបចំបញ្ចប់នូវរបាយការណ៍ស្តីពីការពិនិត្យឡើងវិញនូវមុខងាររបស់ក្រសួងចំនួន៥ ដែលក្នុងនោះរួមមាន៖ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសុខាភិបាល ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ និង២) ការរៀបចំ និងអនុម័តលិខិតបទដ្ឋានគតិយុត្តស្តីពីមុខងារជាជម្រើសរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងន័យជំរុញឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានការផ្តួចផ្តើមគំនិតកាន់តែច្រើនក្នុងក្របខ័ណ្ឌនៃការអនុវត្តមុខងារជាអាណត្តិទូទៅរបស់ខ្លួន។ លេខាធិការដ្ឋាន គ.ជ.អ.ប គឺជាស្ថាប័នទទួលខុសត្រូវក្នុងការសម្របសម្រួលលើកិច្ចការនេះ។

**វឌ្ឍនភាព៖**

ក្នុងរយៈពេល០៦ខែដើមឆ្នាំនេះ ស្ថានភាពនៃការរៀបចំបញ្ចប់របាយការណ៍ស្តីពីការពិនិត្យមើលឡើងវិញនូវមុខងាររបស់ក្រសួង ស្ថាប័នពុំទាន់ត្រូវបានសម្រេចទាំងស្រុងតាមសូចនាករដែលបានកំណត់ឡើយ។ ជារួម ក្នុងចំណោមក្រសួងចំនួន៥ដែលបានកំណត់ មានក្រសួងចំនួន៣ គឺក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា និង ក្រសួងអប់រំ យុវជន និងកីឡា ដែលបានរៀបចំបញ្ចប់នូវរបាយការណ៍ស្តីពីការពិនិត្យមើលឡើងវិញនូវមុខងាររបស់ខ្លួន។

បើទោះបីជាក្រសួងចំនួន២ផ្សេងទៀតពុំបានរៀបចំបញ្ចប់នូវរបាយការណ៍ស្តីពីការពិនិត្យមើលឡើងវិញនូវមុខងាររបស់ខ្លួនតាមពេលកំណត់ក្តី ក៏កិច្ចដំណើរការរៀបចំរបាយការណ៍របស់ក្រសួងទាំងនោះស្ថិតក្នុងស្ថានភាពរីកចម្រើនទៅមុខយ៉ាងល្អ ដែលអាចឈានទៅការរៀបចំបញ្ចប់នៅក្នុងត្រីមាសទី៣ខាងមុខនេះ។ ជាមួយគ្នានេះដែរ ផ្អែកលើសេចក្តីព្រាងរបាយការណ៍ទាំងនេះ ការរៀបចំអនុវត្តសាកល្បងនូវការផ្ទេរមុខងារមួយចំនួនក្នុងវិស័យសុខាភិបាល អនាម័យ និងទឹកស្អាតជនបទរបស់ក្រសួងសុខាភិបាល និងក្រសួងអភិវឌ្ឍន៍ជនបទ ក៏ត្រូវបាន រៀបចំជាបណ្តើរៗផងដែរ ក្រោមការសម្របសម្រួលរបស់លេខាធិការដ្ឋាន គ.ជ.អ.ប។

ក្រៅពីក្រសួងចំនួន៥ដែលបានកំណត់ខាងលើ ក្រសួងដែលស្ថិតក្នុងវិស័យអាទិភាពចំនួន២ ផ្សេងទៀត រួមមាន ក្រសួងបរិស្ថាន និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក៏បាន និង កំពុងរៀបចំបញ្ចប់របាយការណ៍ស្តីពីបញ្ជីវិភាគមុខងាររបស់ខ្លួនផងដែរ។

ដោយឡែក លេខាធិការដ្ឋាន គ.ជ.អ.ប បានសម្របសម្រួលរៀបចំនូវសេចក្តីព្រាងអនុក្រឹត្យស្តី ពីការជ្រើសរើស ការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារជាជម្រើសដោយរដ្ឋបាលថ្នាក់ក្រោម ជាតិ ដើម្បីកំណត់នូវគោលការណ៍ នីតិវិធី សម្រាប់ការជ្រើសរើស ការគ្រប់គ្រង ការចាត់ចែង និងការ អនុវត្តនូវមុខងារជាជម្រើសរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ សំដៅលើកកម្ពស់ការផ្តល់សេវា និងការ អភិវឌ្ឍមូលដ្ឋានប្រកបដោយគណនេយ្យភាព តម្លាភាព ប្រសិទ្ធភាព សមធម៌ និងឆ្លើយតបទៅនឹងតម្រូវ ការរបស់ប្រជាពលរដ្ឋក្នុងក្របខ័ណ្ឌនៃអាណត្តិទូទៅរបស់ខ្លួន។ សេចក្តីព្រាងអនុក្រឹត្យនេះ ត្រូវបាន រៀបចំដោយមានការពិភាក្សាពិគ្រោះយោបល់ជាមួយតំណាងរដ្ឋបាលថ្នាក់ក្រោមជាតិ តំណាងក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធតាមរយៈកិច្ចប្រជុំ និងសិក្ខាសាលានានា។ សេចក្តីព្រាងអនុក្រឹត្យនេះគ្រោងនឹង ដាក់ឆ្លងកិច្ចប្រជុំគ.ជ.អ.ប លើកទី៩ ដើម្បីពិនិត្យសម្រេច។

**បញ្ហាប្រឈម៖**

បញ្ហាប្រឈមសំខាន់ដែលធ្វើឲ្យមានភាពយឺតយ៉ាវក្នុងការរៀបចំបញ្ចប់នូវរបាយការណ៍ស្តីពីការ ពិនិត្យមើលឡើងវិញនូវមុខងាររបស់ក្រសួងស្ថាប័ន គឺមានភាពសាំញ៉ាំនៃការកំណត់នូវមុខងារ ព្រម ទាំងធនធានហិរញ្ញវត្ថុ និងធនធានមនុស្សដែលកំពុងត្រូវបានប្រើប្រាស់សម្រាប់អនុវត្តនូវមុខងារទាំង នេះ ដែលតម្រូវឲ្យមានការសិក្សា ពិនិត្យ និងពិភាក្សាយ៉ាងហ្មត់ចត់លើលិខិតបទដ្ឋានគតិយុត្ត និងស្ថាន ភាពនៃការអនុវត្តជាក់ស្តែងរបស់ក្រសួង ស្ថាប័ននីមួយៗ។

ភាពស្មុគស្មាញនៃកិច្ចការនេះ តម្រូវឲ្យមានឆន្ទៈ និងផ្តោតយកចិត្តទុកដាក់យ៉ាងច្បាស់លាស់ពី ក្រសួង ស្ថាប័ននានាដើម្បីជំរុញកិច្ចដំណើរការនេះ ព្រមទាំងតម្រូវឲ្យមានការគាំទ្រផ្នែកបច្ចេកទេសក្នុង កម្រិតសមស្របមួយពីលេខាធិការដ្ឋាន គ.ជ.អ.ប និងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធនានា។ ភាពស្ទាក់ស្ទើរ និង ការអូសបន្លាយនូវការផ្ទេរមុខងារពីក្រសួង ស្ថាប័ននានាកំពុងក្លាយជាបញ្ហាប្រឈមសំខាន់បំផុតមួយ នៅក្នុងដំណាក់កាលបច្ចុប្បន្ន និងការឈានទៅសម្រេចបាននូវគោលដៅរបស់កំណែទម្រង់ ដែលមាន គោលបំណងលើកកម្ពស់ការទទួលខុសត្រូវរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្តល់សេវា សាធារណៈ នានាជូនប្រជាពលរដ្ឋ។

**ដំណោះស្រាយ៖**

ដើម្បីធានាថា នៅចុងឆ្នាំ២០១៤ ក្រសួងទាំង៥ដែលស្ថិតក្នុងវិស័យអាទិភាពធ្វើការសម្រេច យ៉ាងច្បាស់លាស់អំពីមុខងារ និងធនធាន ព្រមទាំងក្របខ័ណ្ឌពេលវេលាយ៉ាងច្បាស់លាស់មួយសម្រាប់ ផ្ទេរមុខងារ និងធនធានទាំងនោះឲ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ លេខាធិការដ្ឋាន គ.ជ.អ.ប ត្រូវបន្ត និងពង្រឹងបន្ថែមនូវការសម្របសម្រួល និងការគាំទ្រផ្នែកបច្ចេកទេសដល់ក្រសួង ស្ថាប័នពាក់ព័ន្ធ។

ជាមួយគ្នានេះដែរ ក្រសួង ស្ថាប័ននីមួយៗចាំបាច់ត្រូវដាក់បញ្ចូលកិច្ចការទាំងនេះជាអាទិភាពមួយយ៉ាងច្បាស់លាស់ទៅក្នុងផែនការយុទ្ធសាស្ត្ររយៈពេលមធ្យមរបស់ខ្លួន។

**៤. គណនេយ្យភាពសង្គម**

គណនេយ្យភាពសង្គម គឺជាអាទិភាពដ៏សំខាន់មួយដែលត្រូវបានកំណត់នៅក្នុងឯកសារពន្យារពេលផអ៣ ដោយផ្អែកលើផែនការយុទ្ធសាស្ត្រស្តីពីគណនេយ្យភាពសង្គមសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដែលបានដាក់ចេញដោយ គ.ជ.អ.ប នាខែកក្កដា ឆ្នាំ២០១៣ កន្លងមកនេះ។ គោលបំណងសំខាន់នៃការងារគណនេយ្យភាពសង្គម គឺដើម្បីពង្រឹងនូវការប្រើប្រាស់សិទ្ធិរបស់ប្រជាពលរដ្ឋ សហគមន៍មូលដ្ឋានក្នុងចូលរួមពង្រឹងការចាត់ចែង ការប្រើប្រាស់ធនធាន និងការផ្តល់សេវាសាធារណៈនៅរដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈការបង្កលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋ និងសហគមន៍មូលដ្ឋានក្នុងការទទួលបាននូវព័ត៌មាន និងចូលរួមតាមដានត្រួតពិនិត្យលើការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

សូចនាករសំខាន់សម្រាប់ការវាស់វែងស្ថានភាពនៃការអនុវត្តការងារគណនេយ្យភាពសង្គម នៅក្នុង០៦ខែដើមឆ្នាំនេះគឺ ការសាកល្បងនូវឧបករណ៍នានាសម្រាប់ការអនុវត្តផែនការយុទ្ធសាស្ត្រស្តីពីគណនេយ្យភាពសង្គម ដើម្បីធ្វើជាមូលដ្ឋានក្នុងការរៀបចំលិខិតបទដ្ឋានគតិយុត្ត និងសៀវភៅណែនាំសម្រាប់អនុវត្តការងារគណនេយ្យភាព សង្គមនៅតាមស្រុកគោលដៅនៅក្នុងចុងឆ្នាំ២០១៤។

**វឌ្ឍនភាព៖**

ក្នុងរយៈពេល០៦ខែដើមឆ្នាំនេះ ស្ថានភាពនៃអនុវត្តការងារគណនេយ្យភាពសង្គមដែលបានកំណត់នៅក្នុងផែនការសកម្មភាព និងថវិកាឆ្នាំ២០១៤ ត្រូវបានសម្រេចតាមចំណុចដៅដែលបានគ្រោងទុក។ ឧបករណ៍ចាំបាច់នានាសម្រាប់ការអនុវត្តការងារគណនេយ្យភាពសង្គម រួមមាន ឯកសារបណ្តុះបណ្តាល ប័ណ្ណផ្តល់ពិន្ទុរបស់ប្រជាពលរដ្ឋ ឧបករណ៍នានាសម្រាប់ប្រមូលព័ត៌មាន ផ្ទាំងរូបភាពសម្រាប់ការផ្សព្វផ្សាយព័ត៌មាន និងកូនសៀវភៅតូចៗ ដែលមានលក្ខណៈងាយយល់ និងងាយប្រើប្រាស់នូវព័ត៌មានសំខាន់ៗពាក់ព័ន្ធនឹងសិទ្ធិរបស់ប្រជាពលរដ្ឋ ស្តង់ដារនៃការផ្តល់សេវា ការប្រើប្រាស់ថវិកា និងការអនុវត្តការងារនានា ត្រូវបានរៀបចំ និងអនុវត្តសាកល្បងនៅក្នុងស្រុកគោលដៅចំនួន២២ស្រុក។ ផ្អែកលើលទ្ធផលនៃការអនុវត្តសាកល្បងនេះ សេចក្តីណែនាំស្តីពីនីតិវិធីអនុវត្តការងារគណនេយ្យភាព ត្រូវបានរៀបចំជាសេចក្តីព្រាង ដើម្បីធ្វើការពិភាក្សា ពិគ្រោះយោបល់ និងអនុម័តដាក់ឲ្យប្រើប្រាស់នៅចុងឆ្នាំ២០១៤។ ដោយឡែកផែនការអនុវត្តរយៈពេល៣ឆ្នាំនៃការងារគណនេយ្យភាពសង្គមក៏ត្រូវបានរៀបចំជាសេចក្តីព្រាងដោយមានការពិភាក្សា និងផ្តល់យោបល់ពីអ្នកពាក់ព័ន្ធនានាដែលគ្រោងនឹងដាក់ជូន គ.ជ.អ.ប. ពិនិត្យ និងអនុម័តនៅចុងឆ្នាំនេះ។

**បញ្ហាប្រឈម៖**

ទោះបីការងារគណនេយ្យភាពសង្គមត្រូវបានអនុវត្ត និងសម្រេចបានតាមចំណុចដៅដែលបានគ្រោងទុកក៏ដោយ ក៏ប៉ុន្តែ ដោយសារកិច្ចការនេះជាការងារថ្មី ដែលតម្រូវឲ្យមានកិច្ចសហការគ្នាក្នុងការ

អនុវត្តរួមគ្នាយ៉ាងជិតស្និទ្ធរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គការសង្គមស៊ីវិល ដូច្នេះតម្រូវឲ្យមានការពិនិត្យពិភាក្សា និងពិគ្រោះយោបល់យ៉ាងច្រើនក្នុងចំណោមអ្នកពាក់ព័ន្ធទាំងអស់ក្នុងការរៀបចំឯកសារ សម្ភារៈ និងឧបករណ៍ចាំបាច់នានា។ លើសពីនេះ ដើម្បីធានានូវភាពជោគជ័យក្នុងការចាប់ផ្តើមអនុវត្តកិច្ចការថ្មីនេះ បានតម្រូវឲ្យមានការអនុវត្តសាកល្បងជាច្រើនលើកច្រើនសារទាំងក្នុងការរៀបចំ និងប្រើប្រាស់ឯកសារ សម្ភារៈ និងឧបករណ៍ទាំងនោះ។ ដំណើរការទាំងនេះក៏តម្រូវឱ្យមានការប្រើប្រាស់ពេលវេលាសមស្របមួយ និងទាមទារឱ្យលេខាធិការដ្ឋាន គ.ជ.អ.ប ត្រូវជ្រើសរើសមន្ត្រី និងទីប្រឹក្សាដែលសមត្ថភាព និងបទពិសោធន៍ជាក់លាក់សម្រាប់សម្របសម្រួលកិច្ចការ ព្រមទាំងត្រូវធានាដល់ការរៀបចំថវិកាគាំទ្រដ៏ច្បាស់លាស់មួយដោយមានការចូលរួមពីដៃគូអភិវឌ្ឍផងដែរ។

**ដំណោះស្រាយ៖**

ដើម្បីធានាដល់ការចាប់ផ្តើមអនុវត្តការងារគណនេយ្យភាពសង្គម ឲ្យបានទាន់ពេលវេលា តាមផែនការដែលបានគ្រោងក្នុងឆមាសទី២ លេខាធិការដ្ឋាន គ.ជ.អ.ប ត្រូវផ្តោតការយកចិត្តទុកដាក់ក្នុងការរៀបចំឲ្យមានមន្ត្រី និងទីប្រឹក្សាដែលមានសមត្ថភាពសមស្របសម្រាប់ទទួលខុសត្រូវសម្របសម្រួលកិច្ចការនេះ និងត្រូវខិតខំបន្តកិច្ចសហការជាមួយដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធនានាក្នុងការរៀបចំបញ្ចប់សេចក្តីណែនាំស្តីពីនីតិវិធីអនុវត្តការងារគណនេយ្យភាពសង្គម ដើម្បីដាក់ឲ្យអនុវត្តនៅតាមស្រុក និងឃុំគោលដៅនៅចុងឆ្នាំ២០១៤ និងការស្នើសុំឱ្យអនុម័តលើផែនការអនុវត្ត៣ឆ្នាំនៃការងារគណនេយ្យភាពសង្គមចាប់ពីឆ្នាំ២០១៥ដល់ឆ្នាំ២០១៧។

**៦. លក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ**

ការរៀបចំ និងដាក់ឱ្យអនុវត្តនូវលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ គឺជាអាទិភាពដ៏សំខាន់មួយដែលបានកំណត់ក្នុងផែនការសកម្មភាព និងថវិកាឆ្នាំ២០១៤។ គោលបំណងសំខាន់នៃការរៀបចំ និងដាក់ឲ្យអនុវត្តនូវលក្ខន្តិកៈនេះ គឺដើម្បីបង្កើតនូវប្រព័ន្ធគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិដែលមានលក្ខណៈអចិន្ត្រៃយ៍ ដើម្បីផ្តល់នូវស្វ័យភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រង ចាត់ចែងមន្ត្រី បុគ្គលិករបស់ខ្លួន និងដើម្បីពង្រឹងនូវខ្សែគណនេយ្យភាព និងការទទួលខុសត្រូវរបស់មន្ត្រី បុគ្គលិកទាំងនោះ ចំពោះក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្តតួនាទី ភារកិច្ច និងផ្តល់ សេវាសាធារណៈជូនប្រជាពលរដ្ឋ។

ជាមួយគ្នានេះដែរ ការរៀបចំ និងការដាក់ឲ្យអនុវត្តនូវលក្ខន្តិកៈនេះ ក៏ជាតម្រូវការដ៏ចាំបាច់មួយដើម្បីគាំទ្រដល់យន្តការផ្ទេរបុគ្គលិកនៅក្នុងកិច្ចដំណើរការផ្ទេរមុខងារឲ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ សូចនាករសំខាន់សម្រាប់ការតាមដានស្ថានភាពនៃការអនុវត្តសកម្មភាពជាអាទិភាពនេះក្នុងរយៈពេល ០៦ខែដើមឆ្នាំ គឺការរៀបចំ និងអនុម័តនូវលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ។ កិច្ចការនេះត្រូវបានកំណត់នៅក្នុងអនុកម្មវិធីទី៣ ដែលស្ថិតនៅក្រោមការទទួលខុសត្រូវ ដឹកនាំ និងសម្របសម្រួលរបស់ក្រសួងមុខងារសាធារណៈ។

**វឌ្ឍនភាព៖**

ក្នុងរយៈពេល០៦ខែដើមឆ្នាំនេះ ស្ថានភាពនៃការអនុវត្តនូវអាទិភាពនេះ ពុំទាន់សម្រេចបានតាមសូចនាករនៃចំណុចដៅដែលបានកំណត់ទាំងស្រុងនៅឡើយ។ យ៉ាងណាមិញ ក្រោមការខិតខំប្រឹងប្រែងដឹកនាំ និងសម្របសម្រួលរបស់ក្រសួងមុខងារសាធារណៈ ដោយមានកិច្ចសហការជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប សេចក្តីព្រាងលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ ព្រមទាំងបានដាក់ឆ្លងកិច្ចប្រជុំផ្ទៃក្នុងក្រសួង និងកិច្ចប្រជុំលក្ខណៈអន្តរក្រសួងជាច្រើនលើកដើម្បីពិនិត្យ ពិភាក្សា ពិគ្រោះយោបល់ ដើម្បីកែលំអលើសេចក្តីព្រាងលក្ខន្តិកៈនេះ។

ទោះជាយ៉ាងនេះក្តី ដោយសារមានភាពចាំបាច់របស់រាជរដ្ឋាភិបាលដែលតម្រូវឱ្យមានការពិនិត្យនិងកែសម្រួលនូវគោលការណ៍រួមស្តីពីការរៀបចំមុខងារសាធារណៈរបស់រដ្ឋ ដើម្បីធ្វើមូលដ្ឋានក្នុងការកែលំអនូវប្រព័ន្ធគ្រប់គ្រងមន្ត្រីរាជការទូទាំងប្រទេស អាស្រ័យហេតុនេះ សេចក្តីព្រាងលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិដែលបានរៀបចំរួចហើយនេះ ពុំត្រូវបានបន្តដំណើរការដើម្បីដាក់ជូន គ.ជ.អ.ប និងរាជរដ្ឋាភិបាលពិនិត្យ អនុម័ត និងដាក់ឱ្យអនុវត្តឡើយ ដោយសារតែត្រូវរង់ចាំធ្វើការកែសម្រួលឡើងវិញ ដើម្បីធានាឲ្យមានភាពសមស្របជាមួយនឹងគោលការណ៍រួមស្តីពីការរៀបចំមុខងារសាធារណៈរបស់រដ្ឋដែលនឹងគ្រោងអនុម័ត និងដាក់ចេញឲ្យអនុវត្តដោយរាជរដ្ឋាភិបាលនៅត្រីមាសទី៣ចុងឆ្នាំនេះ។

ក្រៅពីនេះ ដើម្បីផ្តល់ការណែនាំបន្ថែមដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្តនូវអនុក្រឹត្យលេខ៤៩៧ស្តីពីការធ្វើប្រតិភូកម្មអំណាចឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលនៅថ្នាក់ក្រោមជាតិ ក្រសួងមុខងារសាធារណៈ ដោយសហការជាមួយក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋាន គ.ជ.អ.ប បានរៀបចំ និងដាក់ឱ្យអនុវត្តនូវសេចក្តីណែនាំលម្អិតសេចក្តីណែនាំស្តីពីនីតិវិធីនៃការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលដែលបំពេញការងារនៅថ្នាក់ក្រោមជាតិ ព្រមទាំងបានរៀបចំផ្សព្វផ្សាយសេចក្តីណែនាំនេះជូនដល់មន្ត្រីពាក់ព័ន្ធនៃរដ្ឋបាលថ្នាក់ក្រោមជាតិផងដែរ។

ជារួម ទោះបីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករបស់រដ្ឋបាលថ្នាក់ក្រោមជាតិពុំទាន់ត្រូវបានរៀបចំ អនុម័ត និងដាក់ឱ្យអនុវត្តតាមគោលបំណងដែលបានគ្រោងទុកក្តី ក៏វឌ្ឍនភាពដែលគួរឱ្យកត់សម្គាល់ក្នុងរយៈពេល០៦ដើមឆ្នាំនេះ គឺការធានាបាននូវការផ្តល់សិទ្ធិអំណាចជាបណ្តើរៗឱ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រងមន្ត្រីរាជការស៊ីវិលដែលបំពេញការងារនៅថ្នាក់ក្រោមជាតិ តាមរយៈការដាក់ចេញនូវសេចក្តីណែនាំ ដើម្បីជំរុញ និងពង្រឹងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រង និងការចាត់ចែងមន្ត្រី បុគ្គលិករបស់ខ្លួន តាមគោលការណ៍ និងនីតិវិធីនានាដែលបានកំណត់នៅអនុក្រឹត្យលេខ៤៩៧ស្តីពីការធ្វើប្រតិភូកម្មអំណាចឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលនៅថ្នាក់ក្រោមជាតិ។

**បញ្ហាប្រឈម៖**

បញ្ហាប្រឈមពាក់ព័ន្ធនឹងការរៀបចំ ការអនុម័ត និងការដាក់ឲ្យប្រើប្រាស់នូវលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករបស់រដ្ឋបាលថ្នាក់ក្រោមជាតិ គឺភាពយឺតយ៉ាវនៃការដាក់ចេញនូវលក្ខន្តិកៈដោយឡែកនេះ បើប្រៀបធៀបទៅនឹងក្របខ័ណ្ឌពេលវេលាដែលបានកំណត់ ដោយសារមូលហេតុដូចបានគូសបញ្ជាក់ពីខាងលើ។ ជាមួយគ្នានេះដែរ ភាពយឺតយ៉ាវក្នុងការរៀបចំ និងដាក់ឲ្យអនុវត្តនូវសេចក្តីណែនាំលម្អិតសម្រាប់អនុវត្តនូវអនុក្រឹត្យលេខ៤៩៧ស្តីពីការធ្វើប្រតិភូកម្មអំណាចឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលនៅថ្នាក់ក្រោមជាតិ និងភាពខ្វះចន្លោះនៃការត្រួតពិនិត្យនិត្យានុកូលភាព និងការគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ក៏ជាកត្តាធ្វើឲ្យប្រសិទ្ធភាពនៃការអនុវត្តនូវសិទ្ធិអំណាច តាមគោលការណ៍ និងនីតិវិធីនានាដែលបានកំណត់ក្នុងអនុក្រឹត្យ៤៩៧ នៅមានកម្រិតនៅឡើយ។

**ដំណោះស្រាយ៖**

ដើម្បីធានាដល់ការសម្រេចបានតាមចំណុចដៅដែលបានកំណត់ ត្រូវបន្តផ្តោតការយកចិត្តទុកដាក់ទៅលើសកម្មភាពសំខាន់ៗមួយចំនួនដូចខាងក្រោម៖

- ផ្អែកលើសេចក្តីព្រាងគោលការណ៍រួមសម្រាប់រៀបចំមុខងារសាធារណៈរបស់រដ្ឋត្រូវធ្វើការពិនិត្យកែសម្រួលជាបណ្តើរៗនូវសេចក្តីព្រាងលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាការដាក់ឆ្លង គ.ជ.អ.ប នូវសេចក្តីព្រាងលក្ខន្តិកៈដោយឡែកនេះ និងដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និងអនុម័តបន្ទាប់ពីគោលការណ៍រួមសម្រាប់រៀបចំមុខងារសាធារណៈរបស់រដ្ឋត្រូវបានអនុម័ត ដាក់ឱ្យប្រើប្រាស់ជាផ្លូវការ។
- ចាប់ផ្តើមរៀបចំជាបណ្តើរៗនូវលិខិតបទដ្ឋានគតិយុត្តនានាសម្រាប់ធានាដល់ការអនុវត្តលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិនៅដើមឆ្នាំ២០១៥
- ពង្រឹងការតាមដាន ត្រួតពិនិត្យ និងគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រងបុគ្គលិកដែលបានធ្វើប្រតិភូកម្ម ដើម្បីធានាតម្លាភាព ប្រសិទ្ធភាពក្នុងការគ្រប់គ្រងបុគ្គលិករបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ស្របតាមតាមគោលការណ៍ និងនីតិវិធីនានាដែលបានកំណត់ក្នុងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**៧. យុទ្ធសាស្ត្រពង្រឹងតួនាទី និងសិទ្ធិអំណាចរបស់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ**

ការពង្រឹងតួនាទី និងសិទ្ធិអំណាចរបស់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ គឺជាអាទិភាពដ៏សំខាន់បំផុតមួយក្នុងការពង្រឹងនូវតម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាពនៃរដ្ឋបាលក្រោមជាតិ ក្នុងការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តនូវមុខងារ និងធនធាន (ទាំងបុគ្គលិក និងហិរញ្ញវត្ថុ) ដែលបានកំណត់ដោយច្បាប់ លិខិតបទដ្ឋានគតិយុត្តនានាសំដៅឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវមានគណនេយ្យភាពដោយផ្ទាល់ចំពោះប្រជាពលរដ្ឋ អាស្រ័យហេតុនេះ ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវអនុវត្តនូវតួនាទី ភារកិច្ច

និងសិទ្ធិអំណាចរបស់ខ្លួនឱ្យបានច្បាស់លាស់ និងប្រកបដោយជោគជ័យ ដោយមានការចូលរួមយ៉ាងទូលំទូលាយពីប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានាក្នុងមូលដ្ឋាន។

ដើម្បីគាំទ្រ និងធានាឱ្យក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិបំពេញតួនាទី ភារកិច្ច និងប្រើប្រាស់សិទ្ធិអំណាចស្របតាមច្បាប់ នៅក្នុងរយៈពេល០៦ខែដើមឆ្នាំនេះ សូចនាករសំខាន់ៗមួយចំនួនត្រូវបានកំណត់ពាក់ព័ន្ធនឹងការរៀបចំលិខិតបទដ្ឋានគតិយុត្ត ដើម្បីគាំទ្រ និងពង្រឹងតួនាទី និងសិទ្ធិអំណាចរបស់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ ដែលក្នុងនោះរួមមាន៖ ១) ការរៀបចំគំរូវិធានគ្រប់គ្រងផ្ទៃក្នុងរបស់រដ្ឋបាលក្រុង ស្រុក ២) ការរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ ការកែប្រែ និងការលុបចោលដីការបស់ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាខណ្ឌ ៣) ការរៀបចំសេចក្តីព្រាងឯកសារបច្ចេកទេសស្តីពីការរៀបចំ ការកែប្រែ និងការលុបចោលដីការបស់ក្រុមប្រឹក្សា ៤) ការរៀបចំសេចក្តីព្រាងឯកសារបច្ចេកទេសសម្រាប់ក្រុមប្រឹក្សាក្នុងការលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋ ៥) ការរៀបចំសេចក្តីព្រាងឯកសារបច្ចេកទេសស្តីពីទំនាក់ទំនងអន្តររដ្ឋបាល ៦) ការរៀបចំសេចក្តីព្រាងឯកសារបច្ចេកទេសស្តីពីការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន និង៧) ការសិក្សា និងវាយតម្លៃអំពីការអភិវឌ្ឍសមត្ថភាព និងការប្រើប្រាស់សិទ្ធិអំណាចរបស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងអាណត្តិទី១របស់ខ្លួន។ លេខាធិការដ្ឋាន គ.ជ.អ.ប. ជាស្ថាប័ន ទទួលបន្ទុកក្នុងការសម្របសម្រួលលើកិច្ចការទាំងនេះ។

**វឌ្ឍនភាព៖**

ក្នុងរយៈពេល០៦ខែដើមឆ្នាំនេះ លេខាធិការដ្ឋានគ.ជ.អ.ប បានសម្រេចលទ្ធផលសំខាន់ៗពាក់ព័ន្ធនឹងការអនុវត្តសកម្មភាពជាអាទិភាពនេះរួមមាន៖

១) ការរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ ការកែប្រែ និងការលុបចោលដីការបស់ក្រុមប្រឹក្សា ក្នុងគោលបំណងធានា និងជំរុញនូវការប្រើប្រាស់សិទ្ធិអំណាចខាងបញ្ញត្តិរបស់ក្រុមប្រឹក្សារដ្ឋបាលរាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាខណ្ឌ។ សេចក្តីព្រាងអនុក្រឹត្យនេះ ត្រូវបានរៀបចំដោយមានការពិគ្រោះយោបល់ច្រើនលើកច្រើនសារជាមួយតំណាងរដ្ឋបាលថ្នាក់ក្រោមជាតិ តំណាងក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធនានាតាមរយៈកិច្ចប្រជុំ និងសិក្ខាសាលានានា។ សេចក្តីព្រាងអនុក្រឹត្យនេះគ្រោងនឹងដាក់ឆ្លងកិច្ចប្រជុំគ.ជ.អ.ប លើកទី៩ ដើម្បីពិនិត្យ និងសម្រេច។

២) ការរៀបចំសេចក្តីព្រាងនៃឯកសារបច្ចេកទេសស្តីពីការរៀបចំ ការកែប្រែ និងការលុបចោលដីការបស់ក្រុមប្រឹក្សា ដែលជាឯកសារដ៏សំខាន់សម្រាប់ជួយគាំទ្រដល់ក្រុមប្រឹក្សាក្នុងការរៀបចំ ការកែប្រែ និងលុបចោលដីការបស់ខ្លួន។ សេចក្តីព្រាងឯកសារបច្ចេកទេសនេះ ត្រូវបានរៀបចំ និងគ្រោងដាក់ឱ្យមានការពិភាក្សា ពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័ន តំណាងក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធនានា បន្ទាប់មកនឹងដាក់ជូនគ.ជ.អ.ប ពិនិត្យសម្រេចដើម្បីដាក់ឱ្យប្រើប្រាស់ក្នុងត្រីមាសទី៤ឆ្នាំ២០១៤។

៣) ការរៀបចំសេចក្តីព្រាងឯកសារបច្ចេកទេសសម្រាប់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការ

លើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋ។ សេចក្តីព្រាងឯកសារបច្ចេកទេសនេះត្រូវបានពិគ្រោះយោបល់ជាមួយតំណាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធមួយចំនួន ហើយគ្រោងនឹងដាក់ជូន គ.ជ.អ.ប ពិនិត្យសម្រេច ដើម្បីដាក់ឱ្យប្រើប្រាស់ក្នុងត្រីមាសទី៤ឆ្នាំ២០១៤។

៤) ការរៀបចំសេចក្តីព្រាងបឋមនៃឯកសារបច្ចេកទេសស្តីពីទំនាក់ទំនងអន្តររដ្ឋបាល។ ឯកសារបច្ចេកទេសនេះនឹងត្រូវពិភាក្សា ពិគ្រោះយោបល់ ជាមួយក្រសួង ស្ថាប័ន តំណាងក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធនានាក្នុងត្រីមាសទី៤ឆ្នាំ២០១៤ បន្ទាប់មកនឹងដាក់ជូនគ.ជ.អ.ប ពិនិត្យសម្រេច ដើម្បីដាក់ឱ្យប្រើប្រាស់ក្នុងត្រីមាសទី១ឆ្នាំ២០១៥។

៥) ការរៀបចំសេចក្តីព្រាងបឋមនៃឯកសារបច្ចេកទេសស្តីពីការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន។ ឯកសារបច្ចេកទេសនេះ នឹងត្រូវពិភាក្សា ពិគ្រោះយោបល់ ជាមួយក្រសួង ស្ថាប័ន តំណាងក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធនានា ក្នុងត្រីមាសទី៤ឆ្នាំ២០១៤ បន្ទាប់មកនឹងដាក់ជូនគ.ជ.អ.ប ពិនិត្យសម្រេច ដើម្បីដាក់ឱ្យប្រើប្រាស់ក្នុងត្រីមាសទី១ឆ្នាំ២០១៥។

៦) ការសិក្សា និងចងក្រងមេរៀននិងបទពិសោធន៍នានានៃការគាំទ្រដល់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ជាឯកសារជំនួយដ៏សំខាន់សម្រាប់ក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធនានា ពិសេសសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីសិក្សាស្វែងយល់អំពីកត្តាជោគជ័យ និងបញ្ហាប្រឈមនានារបស់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ ដែលបានជួបប្រទះក្នុងអាណត្តិទី១របស់ខ្លួន។ សេចក្តីព្រាងបឋមនៃរបាយការណ៍អំពីមេរៀន និងបទពិសោធន៍នានា ត្រូវបានចងក្រងបញ្ចប់ ហើយគ្រោងរៀបចំឱ្យមានការចូលរួមផ្តល់យោបល់ដោយក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធនានាក្នុងត្រីមាសទី៤ឆ្នាំ២០១៤។

ក្រៅពីសម្រេចបាននូវលទ្ធផលចម្បងៗដូចបានបង្ហាញខាងលើ ការរៀបចំសេចក្តីព្រាងគំរូវិធានផ្ទៃក្នុងរបស់រដ្ឋបាលក្រុង ស្រុក នៅពុំទាន់បានសម្រេចតាមផែនការសកម្មភាព និងថវិកាឆ្នាំ២០១៤នៅឡើយ។

**បញ្ហាប្រឈមៈ**

ទោះបីលេខាធិការដ្ឋានគ.ជ.អ.ប ខិតខំប្រឹងប្រែងសម្រេចបាននូវលទ្ធផលសំខាន់ៗក្នុងរយៈពេល០៦ខែដើមឆ្នាំនេះក៏ដោយ ប៉ុន្តែលិខិតបទដ្ឋាន និងឯកសារបច្ចេកទេសមួយចំនួនពុំត្រូវបានរៀបចំបញ្ចប់តាមពេលវេលាដែលបានឡើយ។ មូលហេតុនៃការយឺតយ៉ាវក្នុងការរៀបចំលិខិតបទដ្ឋាន និងឯកសារបច្ចេកទេសទាំងនេះ គឺដោយសារអង្គភាពវិភាគ និងអភិវឌ្ឍន៍គោលនយោបាយនៃលេខាធិការដ្ឋាន គ.ជ.អ.ប ដែលជាអង្គភាពស្នូលទទួលខុសត្រូវក្នុងការរៀបចំលិខិតបទដ្ឋានទាំងនេះ មានមន្ត្រីពុំគ្រប់គ្រាន់សម្រាប់ធានារ៉ាប់រងលើបន្ទុកការងារយ៉ាងច្រើននាពេលដើមឆ្នាំ និងម្យ៉ាងទៀត លិខិតបទដ្ឋានគតិយុត្តទាំងនេះ ទាមទារឱ្យមានការពិភាក្សា ពិគ្រោះយោបល់ជាមួយ ក្រសួង ស្ថាប័ន អ្នកពាក់ព័ន្ធទាំងថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ និងការចុះប្រមូលព័ត៌មាន ពិគ្រោះយោបល់នៅតាមមូលដ្ឋានជាក់ស្តែង ដែលកិច្ចការទាំងនេះតម្រូវឲ្យមានពេលវេលាយ៉ាងសមស្របមួយ។

**ដំណោះស្រាយ៖**

ដើម្បីដោះស្រាយបញ្ហាប្រឈមនេះ លេខាធិការដ្ឋានគ.ជ.អ.ប ត្រូវបន្តជំរុញកិច្ចសហការជាមួយតំណាងក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធនានាក្នុងការរៀបចំ បញ្ចប់លិខិតបទដ្ឋានដែលនៅសេសសល់ ជាពិសេសការរៀបចំបញ្ចប់នូវសេចក្តីព្រាងគំរូវិធានគ្រប់គ្រងផ្ទៃក្នុងរបស់រដ្ឋបាលក្រុង ស្រុក ដោយកំណត់ក្របខណ្ឌពេលវេលាយ៉ាងជាក់លាក់ ដើម្បីធានាដល់ដាក់ឆ្លង គ.ជ.អ.ប ពិនិត្យ និងសម្រេចនៅចុងឆ្នាំ២០១៤។

**៨. ប្រព័ន្ធកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ**

ការរៀបចំ និងដាក់ចេញនូវឯកសារគោលនយោបាយស្តីពីប្រព័ន្ធកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ គឺជាអាទិភាពមួយនៃផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ២០១៤។ គោលបំណងសំខាន់នៃការរៀបចំ និងដាក់ចេញនូវឯកសារគោលនយោបាយនេះ គឺដើម្បីផ្តល់នូវគោលការណ៍ណែនាំតម្រង់ទិសសម្រាប់ការកែលំអនូវប្រព័ន្ធកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលមាននាពេលបច្ចុប្បន្ន ឲ្យមានលក្ខណៈឆ្លុះបញ្ចាំងយ៉ាងសមស្របទៅតាមចរិតលក្ខណៈផ្សេងៗគ្នានៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ធានានូវដាក់បញ្ចូលនូវផែនការរបស់វិស័យទាំងឡាយដែលប្រតិបត្តិការក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងដើម្បីធានាដល់ការបង្កើនប្រសិទ្ធភាពនៃការធ្វើសេចក្តីសម្រេចចិត្តប្រកបដោយស្វ័យភាពរបស់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ក្នុងការឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ ការជំរុញកិច្ចអភិវឌ្ឍមូលដ្ឋានប្រកបដោយភាពស័ក្តិសិទ្ធិ ដោយផ្អែកលើស្ថានភាពប្រជាពលរដ្ឋ ភូមិសាស្ត្រ និងសក្តានុពលនៅមូលដ្ឋាននីមួយៗ ដើម្បីចូលរួមចំណែកក្នុងការសម្រេចបាននូវគោលដៅនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិប្រកបដោយប្រសិទ្ធភាពផងដែរ។

សូចនាករសំខាន់សម្រាប់ការអនុវត្តអាទិភាពនេះក្នុង០៦ខែដើមឆ្នាំ២០១៤ គឺការរៀបចំ និងដាក់ឲ្យអនុវត្តឯកសារគោលនយោបាយស្តីពីប្រព័ន្ធកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្រសួងផែនការគឺជាស្ថាប័នទទួលខុសត្រូវក្នុងការសម្របសម្រួលអនុវត្តសកម្មភាពនានា ដើម្បីសម្រេចបាននូវសូចនាករសំខាន់ៗដែលបានកំណត់នេះ។

**វឌ្ឍនភាព៖**

ជារួម ស្ថានភាពនៃការអនុវត្តសកម្មភាពជាអាទិភាពនេះ ត្រូវបានសម្រេចដោយបានរៀបចំបញ្ចប់នូវសេចក្តីព្រាងឯកសារគោលនយោបាយស្តីពីប្រព័ន្ធផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងត្រៀមដាក់ឆ្លងកិច្ចប្រជុំ គ.ជ.អ.ប ដើម្បីពិនិត្យ និងអនុម័ត។ ក្នុងការរៀបចំសេចក្តីព្រាងឯកសារគោលនយោបាយនេះ ក្រសួងផែនការ ដោយសហការជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប បានរៀបចំឲ្យមានការពិនិត្យ ពិភាក្សា និងពិគ្រោះយោបល់ជាមួយតំណាងក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធនានាតាមរយៈកិច្ចប្រជុំ និងសិក្ខាសាលាពិគ្រោះយោបល់នានា។

**បញ្ហាប្រឈម៖**

ទោះបីជាសេចក្តីព្រាងគោលនយោបាយត្រូវបានរៀបចំបញ្ចប់ក៏ដោយ ក៏សកម្មភាពនានាពាក់

ព័ន្ធផ្សេងទៀត ពោលគឺការសិក្សានានាដើម្បីកែសម្រួលលិខិតបទដ្ឋានគតិយុត្តសម្រាប់កែលំអប្រព័ន្ធកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិពុំទាន់ត្រូវបានចាប់ផ្តើមអនុវត្តឡើយ។

**ដំណោះស្រាយ៖**

ដើម្បីធានាដល់ការសម្រេចបាននូវចំណុចដៅនានាដែលបានកំណត់សម្រាប់ឆមាសទី២ ត្រូវផ្តោតការយកចិត្តទុកដាក់លើកិច្ចការសំខាន់ៗមួយចំនួនដូចខាងក្រោម៖

- រៀបចំ និងផ្សព្វផ្សាយគោលនយោបាយនេះដល់ក្រសួង ស្ថាប័ន និងដល់រដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់ បន្ទាប់ពីគោលនយោបាយនេះត្រូវបានអនុម័តដោយ គ.ជ.អ.ប
- ពិនិត្យ កែសម្រួល ឬរៀបចំលិខិតបទដ្ឋានគតិយុត្ត និងសេចក្តីណែនាំនានាពាក់ព័ន្ធនឹងការកសាងផែនការនៅថ្នាក់ក្រោមជាតិ ដើម្បីធានាដល់ការចាប់ផ្តើមការបណ្តុះបណ្តាលអំពីប្រព័ន្ធកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលបានកែសម្រួលចាប់ពីដើមឆ្នាំ២០១៥។

### ៩. ការពង្រឹងប្រព័ន្ធត្រួតពិនិត្យមើលពីលើ ឬអធិការកិច្ច

ការពង្រឹងប្រព័ន្ធត្រួតពិនិត្យមើលពីលើ ឬអធិការកិច្ចលើការអនុវត្តការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ គឺជាកិច្ចការដ៏ចាំបាច់មួយនៃកិច្ចដំណើរការកំណែទម្រង់។ គោលបំណងសំខាន់នៃការពង្រឹងប្រព័ន្ធត្រួតពិនិត្យមើលពីលើ គឺដើម្បីធានាថា រដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់គ្រង ចាត់ចែង អនុវត្តនូវមុខងារ និងធនធានផ្ទាល់របស់ខ្លួន ព្រមទាំងមុខងារ និងធនធាននានាដែលបានផ្ទេរឲ្យ ស្របតាមច្បាប់ លិខិតបទដ្ឋានគតិយុត្តិ នីតិវិធី និងស្តង់ដារនានាដែលបានកំណត់។ សូចនាករសំខាន់ពាក់ព័ន្ធនឹងកិច្ចការនេះ គឺការសិក្សាដើម្បីរៀបចំលិខិតបទដ្ឋានគតិយុត្តនានាសម្រាប់ការពង្រឹងនូវប្រព័ន្ធត្រួតពិនិត្យមើលពីលើ ឬអធិការកិច្ច។

**វឌ្ឍនភាព៖**

ផ្អែកលើលទ្ធផលនៃការអនុវត្តជាក់ស្តែងក្នុង០៦ខែដើមឆ្នាំនេះ សូចនាករនេះពុំទាន់ត្រូវបានសម្រេចតាមការកំណត់ឡើយ។ ក្នុងការអនុវត្តកិច្ចការនេះ តម្រូវឱ្យលេខាធិការដ្ឋាន គ.ជ.អ.ប ជ្រើសរើស និងផ្តល់កិច្ចសន្យាដល់ទីប្រឹក្សាបច្ចេកទេសដែលមានបទពិសោធន៍ពាក់ព័ន្ធ ដើម្បីធ្វើការសិក្សាវិភាគ និងផ្តល់នូវជម្រើសនានាសម្រាប់ការពង្រឹងប្រព័ន្ធត្រួតពិនិត្យពីលើ ឬអធិការកិច្ចនេះ។ ក្នុងរយៈពេល០៦ខែដើមឆ្នាំនេះ លេខាធិការដ្ឋាន គ.ជ.អ.ប បានជ្រើសរើស និងផ្តល់កិច្ចសន្យាដល់ទីប្រឹក្សាបច្ចេកទេស០១រូបសម្រាប់កិច្ចការនេះ។ ការសិក្សាដើម្បីរៀបចំនូវប្រព័ន្ធត្រួតពិនិត្យមើលពីលើនេះ នឹងត្រូវចាប់ផ្តើមក្នុងឆមាសទី២។

**បញ្ហាប្រឈម៖**

បញ្ហាប្រឈមជាចម្បងក្នុងការអនុវត្តសកម្មភាពជាអាទិភាពនេះ គឺភាពយឺតយ៉ាវក្នុងការជ្រើសរើសទីប្រឹក្សាបច្ចេកទេស។ ភាពចន្លោះប្រហោងនៃការត្រួតពិនិត្យមើលពីលើនេះកំពុងបង្កឱ្យមានការខ្វះនូវចំណាត់ការច្បាស់លាស់ និងទាន់ពេលវេលាទៅលើភាពមិនប្រក្រតីមួយចំនួនដែលកំពុងកើតឡើង

ក្នុងការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

**ដំណោះស្រាយ៖**

ដើម្បីធានាដល់ការសម្រេចបានចំណុចដៅដែលបានកំណត់ លេខាធិការដ្ឋាន គ.ជ.អ.ប ត្រូវសហការជាមួយក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធនានា ក្នុងការបន្តជំរុញការសិក្សា និងរៀបចំតាក់តែងលិខិតបទដ្ឋានគតិយុត្តចាំបាច់នានាដើម្បីធានាដល់ការរៀបចំ និងអនុវត្តនូវប្រព័ន្ធនេះចាប់ពីឆ្នាំ២០១៥។

**១០. យុទ្ធសាស្ត្រសម្រាប់ការពង្រឹងសមត្ថភាពផ្នែករដ្ឋបាលរបស់ក្រុង ស្រុក**

ដើម្បីធានាដល់ការបន្តពង្រឹងសមត្ថភាពផ្នែករដ្ឋបាលរបស់ក្រុង ស្រុក ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ២០១៤ បានកំណត់នូវចំណុចដៅសំខាន់ចំនួន២ ដែលត្រូវសម្រេចឱ្យបានក្នុងរយៈពេល ០៦ខែដើមឆ្នាំ២០១៤នេះ។ ចំណុចដៅទាំងនេះរួមមាន (១)ការវិភាជន៍ថវិកាកម្មវិធីឱ្យទៅរដ្ឋបាលក្រុង ស្រុកសម្រាប់គាំទ្រដល់ការជ្រើសរើសមន្ត្រីកិច្ចសន្យា និងការអនុវត្តសកម្មភាពជាក់លាក់នានាដែលពុំអាចរ៉ាប់រងដោយមូលនិធិក្រុង ស្រុក និង (២) ការរៀបចំសៀវភៅណែនាំស្តីពីកិច្ចប្រតិបត្តិការរបស់រដ្ឋបាល ក្រុង ស្រុក។

**វឌ្ឍនភាព៖**

ក្នុងរយៈពេល០៦ដើមឆ្នាំនេះ លេខាធិការដ្ឋាន គ.ជ.អ.ប បានវិភាជន៍ថវិកាកម្មវិធីសម្រាប់គាំទ្រដល់ក្រុង ស្រុកតាមការកំណត់ និងបានអនុញ្ញាតឲ្យរដ្ឋបាលក្រុង ស្រុកនីមួយៗជ្រើសរើសនូវមន្ត្រីកិច្ចសន្យាមួយចំនួន សំដៅជួយគាំទ្រដល់រដ្ឋបាលក្រុង ស្រុក។

ពាក់ព័ន្ធនឹងការរៀបចំសៀវភៅណែនាំស្តីពីនីតិវិធីកិច្ចប្រតិបត្តិការរបស់រដ្ឋបាលក្រុង ស្រុក ក្រោមការសម្របសម្រួលរបស់អគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋានក្រសួងមហាផ្ទៃ សេចក្តីព្រាងបឋមត្រូវបានរៀបចំឡើង និងកំពុងត្រូវបានដាក់ឱ្យពិនិត្យ ពិភាក្សា និងពិគ្រោះយោបល់ជាមួយតំណាងក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធនានា ដើម្បីឈានទៅរៀបចំបញ្ចប់ និងដាក់ឱ្យប្រើប្រាស់នៅចុងឆ្នាំ២០១៤នេះ។

**បញ្ហាប្រឈម៖**

ទោះបី លេខាធិការដ្ឋាន គ.ជ.អ.ប បានវិភាជន៍ថវិកាកម្មវិធីឱ្យទៅរដ្ឋបាលក្រុង ស្រុក ដើម្បីគាំទ្រដល់ការជ្រើសរើសមន្ត្រីកិច្ចសន្យាមួយចំនួនទៅតាមតម្រូវការជាក់ស្តែងក្តី ក៏ការជ្រើសរើសមន្ត្រីកិច្ចសន្យានៅតាមរដ្ឋបាលក្រុង ស្រុកមួយចំនួនពុំទាន់បានសម្រេចតាមការគ្រោងនៅឡើយ ដោយសារនៅតាមស្រុកដែលស្ថិតនៅតាមតំបន់ដាច់ស្រយាលមួយចំនួន ពុំមានបេក្ខជនដែលមានលក្ខណៈសមស្របតាមលក្ខណៈវិនិច្ឆ័យមកដាក់ពាក្យចូលបំរើការងារនៅតាមស្រុកទាំងនោះឡើយ។

**ដំណោះស្រាយ៖**

ដើម្បីដោះស្រាយបញ្ហាខាងលើ លេខាធិការដ្ឋាន គ.ជ.អ.ប ត្រូវពិនិត្យឡើងវិញលើតម្រូវការនៃលក្ខណៈសម្បត្តិ និងក្របខ័ណ្ឌការងាររបស់មន្ត្រីកិច្ចសន្យា និងត្រូវអនុញ្ញាតឲ្យរដ្ឋបាលក្រុង ស្រុកទាំង

នោះធ្វើការផ្សព្វផ្សាយដំណឹងជ្រើសរើសមន្ត្រីកិច្ចសន្យាទាំងនោះឱ្យបានទូលំទូលាយបន្ថែមទៀត ដើម្បីផ្តល់ឱកាសដល់បេក្ខជនជាសិស្សនិស្សិតដែលទើបបញ្ចប់ការសិក្សាមានលទ្ធភាពដាក់ពាក្យប្រឡងចូលបម្រើការងារជាមន្ត្រីកិច្ចសន្យានៅតាមស្រុកក្នុងតំបន់ដាច់ស្រយ៉ាលទាំងនោះ។

**១១. សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ ៖**

ការបង្កើតសមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ គឺជាកិច្ចការដ៏មានសារៈសំខាន់ ដើម្បីធ្វើជាបណ្តាញសម្រាប់ការចែករំលែកព័ត៌មាន ចំណេះដឹងក្នុងចំណោមសមាជិកក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ និងសម្រាប់ធ្វើជាបណ្តាញប្រមូលសម្លេង តម្រូវការ បញ្ហារួមរបស់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីដាក់ជូនរាជរដ្ឋាភិបាលធ្វើជាមូលដ្ឋានក្នុងការកែលំអការរៀបចំកម្មវិធីកំណែទម្រង់។ សូចនាករសំខាន់ពាក់ព័ន្ធនឹងការបង្កើតសមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិនេះ គឺការបន្តរៀបចំបង្កើតនូវសមាគមក្រុមប្រឹក្សាក្រុង ស្រុក និងឃុំ សង្កាត់នៅតាមខេត្តដែលនៅសេសសល់ទាំង១៣ (ដែលជាខេត្តពុំទាន់បានបង្កើតសមាគមក្រុមប្រឹក្សាក្រុង ស្រុក និងឃុំ សង្កាត់នៅក្នុងឆ្នាំ២០១៣) និងការរៀបចំកែសម្រួលរចនាសម្ព័ន្ធនៃអគ្គលេខាធិការដ្ឋានសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាឃុំ សង្កាត់ឱ្យក្លាយទៅជាអគ្គលេខាធិការដ្ឋានសម្រាប់គាំទ្រដល់សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិទាំងមូល។

**វឌ្ឍនភាព៖**

ជារួម ស្ថានភាពនៃការអនុវត្តអាទិភាពនេះ ត្រូវបានសម្រេចតាមសូចនាករនៃចំណុចដៅដែលបានគ្រោង ពោលគឺសមាគមក្រុមប្រឹក្សាក្រុង ស្រុក និងឃុំ សង្កាត់នៅតាមខេត្តទាំង១៣ត្រូវបានរៀបចំបង្កើត និងត្រូវបានដាក់បញ្ចូលជាសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាក្រុង ស្រុក និងឃុំ សង្កាត់ និងរចនាសម្ព័ន្ធនៃអគ្គលេខាធិការដ្ឋានសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាឃុំ សង្កាត់ក៏ត្រូវបានសិក្សា ពិនិត្យ និងកែសម្រួល និងកំពុងត្រូវបានពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធនានា។

**បញ្ហាប្រឈម៖**

ទោះបីការបង្កើតសមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិទាំងពីរត្រូវបានរៀបចំរួចរាល់ និងការប្រព្រឹត្តទៅនៃសមាគមទាំងនោះត្រូវបានដាក់ឱ្យដំណើរការជាបណ្តើរៗក្តី ក៏ប៉ុន្តែដោយសារយន្តការគាំទ្រពីអគ្គលេខាធិការដ្ឋានសមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ ពុំទាន់ត្រូវបានរៀបចំឱ្យមានភាពច្បាស់លាស់នៅឡើយ អាស្រ័យហេតុនេះ ការប្រព្រឹត្តទៅនៃសមាគមក្រុមប្រឹក្សាតាមរដ្ឋបាលនីមួយៗនៅពុំមានភាពរលូននៅឡើយ ទាំងក្នុងការចែករំលែកព័ត៌មាន ចំណេះដឹង ទាំងក្នុងការប្រមូលសម្លេងរួម ព្រមទាំងពង្រឹងភាពជាម្ចាស់របស់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ។

**ដំណោះស្រាយ៖**

ដើម្បីដោះស្រាយបញ្ហាប្រឈមខាងលើ តំណាងសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងតំណាងសមាគមក្រុមប្រឹក្សារាជធានី ខេត្ត ត្រូវបន្តជំរុញការពិភាក្សា និងស្វែងរកការឯកភាពគ្នាលើជម្រើសសមស្រប ដើម្បីធានានូវការកែសម្រួលរចនាសម្ព័ន្ធអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សារដ្ឋបាល

លថ្នាក់ក្រោមជាតិឲ្យមានលក្ខណៈច្បាស់លាស់ និងមានលទ្ធភាពផ្តល់ការគាំទ្រដល់សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់ប្រកបដោយប្រសិទ្ធភាព ចាប់ពីចុងឆ្នាំ២០១៤តទៅ។

**១២. ការបញ្ជ្រាបយេនឌ័រ និងការពង្រឹងភាពអង់អាចដល់ស្ត្រី**

ការបញ្ជ្រាបយេនឌ័រ និងការពង្រឹងភាពអង់អាចដល់ស្ត្រីគឺជាកិច្ចការដ៏មានសារៈសំខាន់មួយនៃកិច្ចដំណើរការកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ គោលបំណងសំខាន់នៃការបញ្ជ្រាបយេនឌ័រ និងការពង្រឹងភាពអង់អាចដល់ស្ត្រី គឺដើម្បីធានាថាស្ថាប័នអនុវត្តកិច្ចដំណើរការកំណែទម្រង់ទាំងអស់ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិត្រូវផ្តោតការយកចិត្តទុកដាក់ខ្ពស់អំពីការលើកកម្ពស់ការចូលរួមរបស់ស្ត្រីនៅក្នុងការអនុវត្តកិច្ចដំណើរការកំណែទម្រង់ពាក់ព័ន្ធនឹងអាណត្តិ និងវិស័យការងាររបស់ខ្លួនដើម្បីធានាដល់ផលប្រយោជន៍យ៉ាងសមធម៌ដល់ស្ត្រី និងក្រុមជនងាយរងគ្រោះនានា។ សូចនាករជាក់លាក់សម្រាប់ការអនុវត្តកិច្ចការនេះក្នុងរយៈពេល០៦ខែដើមឆ្នាំ២០១៤នេះ គឺការរៀបចំបញ្ចប់នូវសវនកម្មយេនឌ័រ និងការសិក្សាវិភាគ ដើម្បីដាក់បញ្ចូលនូវអនុសាសន៍ជាក់លាក់នានានៃសវនកម្មយេនឌ័រទៅក្នុងផអ៣ដំណាក់កាលបន្ទាប់។

**វឌ្ឍនភាព៖**

ជារួមស្ថានភាពនៃការអនុវត្តកិច្ចការជាអាទិភាពនេះ ត្រូវបានសម្រេចតាមចំណុចដៅដែលបានគ្រោងទុក ដែលក្នុងនោះសវនកម្មយេនឌ័រត្រូវបានអនុវត្ត ដោយកិច្ចសហការរវាងលេខាធិការដ្ឋាន គ.ជ.អ.ប និងក្រសួងកិច្ចការនារី។ អនុសាសន៍នានាដែលបានលើកឡើងក្នុងរបាយការណ៍សវនកម្មយេនឌ័រក៏ត្រូវបានសិក្សាដើម្បីដាក់បញ្ចូលទៅក្នុងយុទ្ធសាស្ត្រ និងឯកសារលម្អិតនៃផអ៣ដំណាក់កាលទី២។

**បញ្ហាប្រឈម៖**

ទោះបី របាយការណ៍សវនកម្មយេនឌ័រនៃផអ៣ត្រូវបានរៀបចំរួចរាល់នៅដើមឆ្នាំ២០១៤ក្តី ក៏របាយការណ៍នេះ ពុំទាន់ត្រូវបានផ្សព្វផ្សាយឱ្យបានទំលំទូលាយដល់ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ជាតិ និងអ្នកពាក់ព័ន្ធឡើយ។ អាស្រ័យហេតុនេះ អនុសាសន៍នានាដែលបានលើកឡើងនៅក្នុងរបាយការណ៍នេះពុំទាន់ត្រូវបានយកទៅពិចារណា ដើម្បីចាត់វិធានការកែលំអការអនុវត្តនៅតាមក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិឡើយ។

**ដំណោះស្រាយ៖**

ក្នុង០៦ខែបន្ទាប់ លេខាធិការដ្ឋាន គ.ជ.អ.ប និងក្រសួងកិច្ចការនារីត្រូវបន្តកិច្ចសហការគ្នាដើម្បីពន្លឿនការផ្សព្វផ្សាយរបាយការណ៍សវនកម្មយេនឌ័រ ក្នុងន័យជំរុញឲ្យក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិផ្តោតការយកចិត្តទុកដាក់ក្នុងការបញ្ជ្រាបយេនឌ័រ និងពង្រឹងភាពអង់អាចដល់ស្ត្រីក្នុងកិច្ចការរបស់ខ្លួន។ ស្របពេលជាមួយគ្នានេះដែរ លេខាធិការដ្ឋាន គ.ជ.អ.ប និងក្រសួងកិច្ចការនារីត្រូវបន្តចូលរួមក្នុងកិច្ចដំណើរការរៀបចំតាក់តែងផអ៣ដំណាក់កាលទី២ ដើម្បីធានាថា បញ្ហាយេនឌ័រ និងការពង្រឹងភាពអង់អាចរបស់ស្ត្រីត្រូវបានដាក់បញ្ចូលទៅក្នុងឯកសារផអ៣ដំណាក់កាលទី២យ៉ាងជាក់លាក់ និងច្បាស់លាស់។

## ១៣. ការរៀបចំតាក់តែង ផអ៣ ដំណាក់កាលបន្ទាប់នៃកម្មវិធីជាតិ

ផអ៣ដំណាក់ដំបូងនៃកម្មវិធីជាតិនឹងត្រូវបញ្ចប់នៅចុងឆ្នាំ២០១៤ខាងមុខនេះ អាស្រ័យហេតុនេះការចាប់ផ្តើមរៀបចំតាក់តែងផអ៣ដំណាក់កាលទី២នៃកម្មវិធីជាតិនៅត្រីមាសទី៣នៃឆ្នាំ២០១៤ គឺជាតម្រូវការចាំបាច់ដើម្បីធានាឲ្យមានពេលវេលាគ្រប់គ្រាន់សម្រាប់កិច្ចដំណើរការរៀបចំតាក់តែងផអ៣ដំណាក់ទី២នេះប្រកបដោយការចូលរួមពីគ្រប់តំណាងក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធនានា។ ដើម្បីធានាដល់ការចាប់ផ្តើមរៀបចំតាក់តែងផអ៣ដំណាក់កាលទី២ទាន់ពេលវេលា សូចនាករនៃចំណុចដៅសំខាន់សម្រាប់កិច្ចការនេះ គឺការរៀបចំល័ក្ខខ័ណ្ឌការងារសម្រាប់រៀបចំតាក់តែងផអ៣ដំណាក់កាលបន្ទាប់ និងការជ្រើសរើសក្រុមទីប្រឹក្សា ដើម្បីផ្តល់ការគាំទ្រផ្នែកបច្ចេកទេសក្នុងកិច្ចដំណើរការរៀបចំតាក់តែងផអ៣ដំណាក់កាលទី២នេះ។

**វឌ្ឍនភាព៖**

ល័ក្ខខ័ណ្ឌការងារសម្រាប់ការរៀបចំតាក់តែងផអ៣ដំណាក់កាលទី២ត្រូវបានរៀបចំដោយមានការឯកភាពគ្នាជាមួយដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធ ហើយក្រុមទីប្រឹក្សាចំនួន៥រូប (ទីប្រឹក្សាអន្តរជាតិចំនួន០៣រូប និងទីប្រឹក្សាជាតិចំនួន០២រូប) ក៏ត្រូវបានជ្រើសរើស និងចុះកិច្ចសន្យាជាមួយលេខាធិកាដ្ឋាន គ.ជ.អ.ប ដើម្បីផ្តល់ការគាំទ្រផ្នែកបច្ចេកទេសក្នុងកិច្ចដំណើរការរៀបចំតាក់តែងផអ៣ដំណាក់កាលទី២។

**បញ្ហាប្រឈម៖**

ទោះបី លេខាធិការដ្ឋាន គ.ជ.អ.ប បានផ្តល់កិច្ចសន្យាជាមួយក្រុមទីប្រឹក្សាដើម្បីជួយគាំទ្រផ្នែកបច្ចេកទេសក្នុងកិច្ចដំណើរការរៀបចំតាក់តែងផអ៣ដំណាក់កាលទីពីរនេះក្តី ក៏ដើម្បីធានាដល់ការលើកកម្ពស់ភាពជាម្ចាស់របស់រាជរដ្ឋាភិបាលក្នុងការរៀបចំ និងអនុវត្តកម្មវិធីនៃកិច្ចដំណើរការកំណែទម្រង់តម្រូវឲ្យមានការកំណត់នូវជំហានយ៉ាងច្បាស់លាស់ និងយន្តការសមស្របដើម្បីលើកកម្ពស់ការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធទាំងអស់ ព្រមទាំងត្រូវកំណត់នូវក្របខ័ណ្ឌពេលវេលាជាក់លាក់ក្នុងការរៀបចំតាក់តែងផអ៣ដំណាក់កាលទី២។

## III. សេចក្តីសន្និដ្ឋាន

ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ២០១៤ បានកំណត់នូវវិធីសាស្រ្ត សកម្មភាព ធនធាន ស្ថាប័នទទួលបន្ទុក និងពេលវេលាជាក់លាក់ដើម្បីធានាដល់ការសម្រេចបាននូវអាទិភាពទាំង១៣ ដែលបានកំណត់នៅក្នុងឯកសារពន្យារពេលផអ៣រយៈពេល១ឆ្នាំនៃឆ្នាំ២០១៤។ ដើម្បីធានាដល់ការត្រួតពិនិត្យតាមដាន និងវាស់វែងលើស្ថានភាពនៃការអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ២០១៤ នេះ សូចនាករជាក់លាក់នៃចំណុចដៅតាមអាទិភាពនីមួយៗក៏ត្រូវបានកំណត់ផងដែរ។

ផ្អែកលើស្ថានភាពទូទៅនៃការអនុវត្តជាក់ស្តែងក្នុងរយៈពេល០៦ខែដើមឆ្នាំនេះ ក្នុងចំណោមអាទិភាពទាំង១៣ មានអាទិភាពមួយចំនួនធំត្រូវបានអនុវត្តសម្រេចតាមសូចនាករដែលបានកំណត់ទាំងស្រុង និងអាទិភាពមួយចំនួនតូចដែលពុំទាន់បានសម្រេចតាមសូចនាករដែលបានកំណត់ទាំងស្រុង ដោយសារមូលហេតុចាំបាច់មួយចំនួន ដែលតម្រូវឱ្យពន្យារពេលទៅអនុវត្តនៅក្នុងឆមាសបន្ទាប់។

ទោះបីភាពជាម្ចាស់របស់រាជរដ្ឋាភិបាលក្នុងការដឹកនាំ សម្របសម្រួលកិច្ចដំណើរការជាទូទៅនៃកំណែទម្រង់ត្រូវបានពង្រឹងយ៉ាងមានប្រសិទ្ធភាព ក្នុងការធ្វើឱ្យបានសម្រេចស្ទើរតែទាំងស្រុងទៅតាមសូចនាករដែលបានកំណត់តាមអាទិភាពទាំង១៣ក្តី ក៏នៅមានបញ្ហាប្រឈមជាគន្លឹះមួយចំនួនដែលតម្រូវឲ្យមានការផ្តោតការយកចិត្តទុកដាក់ដោះស្រាយនៅក្នុងឆមាសទី២។ បញ្ហាប្រឈមជាគន្លឹះទាំងនេះរួមមានពាក់ព័ន្ធនឹង៖

- ការបន្តពង្រឹងយន្តការ គ.ជ.អ.ប ដើម្បីធានាដល់ការបង្កើនប្រសិទ្ធភាពនៃការដឹកនាំតម្រង់ទិស ការសម្របសម្រួល និងការគាំទ្រកិច្ចដំណើរការកំណែទម្រង់
- ការបន្តពង្រឹងការគ្រប់គ្រង និងការអនុវត្តមូលនិធិក្រុង ស្រុក ដើម្បីធានាដល់ការបង្កើនប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងស្វ័យភាពនៃការគ្រប់គ្រងហិរញ្ញវត្ថុរបស់ក្រុង ស្រុក និងការបន្តជំរុញដល់ការរៀបចំ និងដាក់ចេញនូវឯកសារគោលនយោបាយ សម្រាប់ផ្តល់គោលការណ៍តម្រង់ទិសក្នុងការរៀបចំបង្កើតប្រភពចំណូលផ្ទាល់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាថារដ្ឋបាលថ្នាក់ក្រោមជាតិអាចមានលទ្ធភាពក្នុងការប្រមូល និងប្រើប្រាស់ចំណូលផ្ទាល់របស់ខ្លួនចាប់ពីឆ្នាំ២០១៥តទៅ
- ការធានាឱ្យមានការផ្ទេរនូវមុខងារ និងការទទួលខុសត្រូវជាបណ្តើរៗ និងយ៉ាងច្បាស់លាស់ដល់រដ្ឋបាលថ្នាក់ក្រោមជាតិ សំដៅលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈចាំបាច់នានាដល់ប្រជាពលរដ្ឋ
- បន្តជំរុញដល់ការរៀបចំកែលំអយន្តការត្រួតពិនិត្យមើលពីលើ ឬអធិការកិច្ច ដើម្បីធានាថារដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់គ្រង ចាត់ចែង និងអនុវត្តនូវមុខងារផ្ទាល់របស់ខ្លួន ព្រមទាំងមុខងារ និងធនធាននានាដែលបានផ្ទេរឲ្យស្របតាមច្បាប់ លិខិតបទដ្ឋានគតិយុត្តិ និងនីតិវិធី និងស្តង់ដារនានាដែលបានកំណត់។

ជារួម ផ្អែកលើលទ្ធផលនៃការអនុវត្តផែនការសកម្មភាព និងថវិកាឆ្នាំ២០១៤ ក្នុងរយៈពេល០៦ ខែដើមឆ្នាំនេះ បានបង្ហាញឱ្យឃើញពីវឌ្ឍនភាពជាច្រើនគួរឱ្យកត់សម្គាល់។ ទោះបីជាមានភាពយឺតយ៉ាវក្នុងការអនុវត្តនូវកិច្ចការជាអាទិភាពមួយចំនួន ដែលបានគ្រោងសម្រាប់អនុវត្តឲ្យបានសម្រេចនៅក្នុងឆមាសទី១នៃឆ្នាំ២០១៤នេះក៏ដោយ ក៏មានការរំពឹងទុកប្រកបដោយភាពជឿជាក់ថានឹងអាចសម្រេចបាននូវកិច្ចការជាអាទិភាពនានាដែលបានកំណត់ក្នុងផែនការសកម្មភាព និងថវិកាឆ្នាំ២០១៤នេះយ៉ាងពិតប្រាកដ។

របាយការណ៍ឆមាសទី១នៃផែនការសកម្មភាពនិងថវិកាឆ្នាំ២០១៤នេះ បានពិនិត្យនិងអនុម័តដោយកិច្ចប្រជុំគ.ជ.អ.ប លើកទី៩ ដែលបានប្រព្រឹត្តទៅ នៅថ្ងៃទី២៥ ខែ កញ្ញា ឆ្នាំ២០១៤។

**រាជធានីភ្នំពេញ ថ្ងៃទី 02 ខែ ... ឆ្នាំ ២០១៤**

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**និងជាប្រធាន គ.ជ.អ.ប**

**ស ខេង**